# ការសំភាសន៍ជាលើកទី២របស់អ៊ំស្រី យ៉ាន់ រឿង

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ យ៉ាន់ រឿង

## ការសង្ខេបជាលើកទី២របស់អ៊ំស្រី យ៉ាន់ រឿង

អ៊ំស្រី យ៉ាន់ រឿង គាត់បានរៀបការនៅក្នុងឆ្នាំ១៩៧៥គ្រាន់តែរៀបការហើយបានមួយឆ្នាំសង្គ្រាមដ៏សែនអាក្រក់ ប៉ុល ពតបានចាប់មានឡើងហើយបានធ្វើបាបប្រជាជនសម្លាប់យ៉ាងសាហាវ ហើយបង្ខំអោយប្រជាជនធ្វើការជាទម្ងន់ហើយមិនអោយអ្វីហូបគ្រប់គ្រាន់។នៅក្នុងជំនាន់ប៉ុល ពតអ៊ំស្រីគឺធ្វើជាគណៈកងដែលមានកូនក្រុម១០នាក់ ហើយគាត់បានជួយដល់ពួកគេអោយបានហូបឆ្អែត ព្រោះគាត់យល់ថាទាំងរូបគេទាំងរូបយើងគឺត្រូវការការហូបដូចគ្នាអ៊ីចឹងគាត់បានធ្វើជាមេកងដ៏ល្អ ។ អ៊ំស្រីបានរៀនច្រើនដែរនៅមុនសង្គ្រាមប៉ុល ពតតែដោយសារទទួលសង្គ្រាមកើតឡើងក៏គាត់ឈប់រៀនហើយអ៊ំគាត់ថាគាត់មិនសូវពូកែអក្សរសាស្រ្តខ្មែរទេតែគាត់ពូកែបារាំងជាងគាត់អាចតែងសេចក្តីជាបារាំង។ ក្រុមគ្រួសារអ្នកធ្វើស្រែចំការហើយអ៊ំស្រីរៀបការជាមួយស្វាមីហើយបានរួមរស់ជាមួយគ្នាហើយគាត់នៅក្នុងជំនាន់ប៉ុល ពតគឺគ្មានកូនទេ នេះក៏ល្អសំរាប់គាត់ហើយបានគេអោយក្មេងស្រីអាយុ១២ឆ្នាំមកចិញ្ចឹមហើយគាត់ក៏ទទួលហើយក្មេងស្រីនោះបានរស់នៅជាមួយគាត់រហូតទាល់តែមានប្តីមានកូនហើយបែកប៉ុល ពតមកអ៊ំបានមានកូនអ៊ីចឹង៧ឆ្នាំបន្ទាប់ពីរៀបការហើយទើបគាត់មានកូន។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ំស្រីម្តងទៀតដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់ជាថ្មីម្តងទៀត។នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ំនៅក្នុងថ្ងៃនេះ ថ្ងៃពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិព្រែកថី ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល

ប្រទេសកម្ពុជា។អ៊ីចឹងកាលពីមុនញ៉ុមបានសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ំអំពីក្រុមគ្រួសារក៏ដូច ជាជីវិតដែលអ៊ំបាននៅពីក្មេងជាមួយក្រុមគ្រួសារថាអ៊ំបានប្រកបរបររកស៊ីអីគេខ្លះអ៊ីចឹង!! អ៊ីចឹងឥលូវចូលដល់ជីវិតរបស់អ៊ំប្រវត្តិសង្គ្រាមនឹងការសិក្សាវិញម្តង។ អ៊ីចឹងអ៊ំសូមប្រាប់ឈ្មោះពេញម្តងទៀតអ៊ំ?

ខ៖ ញ៉ុមហោ?

ក៖ចា៎!!

ខ៖ ឈ្មោះទាំងឪទាំងកូនហោ?

ក៖ ហ្នឹងហើយ!!

ខ៖ តែឈ្មោះញ៉ុមទេហី?

ក៖ទាំងត្រកូល។

ខ៖ យ៉ាន់ រឿង។

ក៖អ៊ីចឹងអ៊ំសំរាប់ចូលដល់ការសិក្សារបស់អ៊ំដោយសារពេលមុនញ៉ុមអត់បានសួរពីការសិក្សារ របស់អ៊ំទេ!! អ៊ំរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ទី៧។

ក៖ ទី៧សម័យទំនើបឬក៏សម័យណា?

ខ៖ សម័យជំនាន់សីហនុ។

ក៖ ហ៊ុំពាក់កណ្តាលហើយអ៊ំ!!មែនទេ?

ខ៖ បើឥឡូវគេធ្វើគ្រូបង្រៀនបាន!!

ក៖ ហើយពេលហ្នឹងចឹបានអ៊ំអត់ព្រមធ្វើគ្រូធ្វើអីគេដែរ?

ខ៖ ពិបាកណាស់។

កៈ អ៊ីចឹងអ៊ំពេលហ្នឹងគេរាប់បញ្ច្រាស់មកវិញ?ទី១២មកវិញអ៊ំណោះមកទី១?

ខៈ ហ្នឹងហើយ។

កៈ អាសម័យរាប់បញ្ច្រាស់?

ខៈ
ហ្នឹងហើយរាប់ពីទី៧ហ្នឹងដល់ពេលយើងប្រលងចូលដល់ទី៧ទៅចូលដល់ទី៦នៅព្រៃកគូច។

កៈ ចាំ!ហើយម៉េចបានឈប់រៀនពេលហ្នឹង?

ខៈ ហ៊ឺវាទាល់ដៃទាល់ជើងហើយ!!ហើយត្រូវគេសង្គ្រាមទៀត!!

កៈហ្ហ៎!!

ខៈហើយដល់គេវ៉ៃគ្នាអ៊ីចឹងលោកគ្រូអត់មានបង្រៀនទេខ្លាចងាប់ហា!!ខ្លាចយួនអីចាប់អញ្ចឹង
ហើយអញ្ចឹងគេឡើងរត់ទៅលើអស់ហើយរត់ទៅភ្នំពេញម្ល៉ោះហើយអត់បានបង្រៀនចប់ត្រឹម
ហ្នឹងទៅ។

កៈហ្ហ៎អញ្ចឹងដោយសារមូលហេតុសង្គ្រាមធ្វើអោយអ៊ំបានឈប់ហ្នឹង?

ខៈ ចាំ!!

កៈ ចង្រៃយកសង្គ្រាម!!!

ខៈ វាមានទាហានមានប៉ុល
ពតអញ្ចឹងគេអត់ហ៊ានចូលមកទេគេនៅឆ្ងាយៗមីអូនណាស់!កៈចាំ!!ខៈ
គ្រូៗនៅហ្នឹងក៏គេឡើងទៅភ្នំពេញអស់ហើយដែរ។

កៈចាំ!!

ខៈ អត់នៅទេ!!

កៈ តែអ៊ំគ្រូៗនៅពេលជំនាន់ហ្នឹងសុទ្ធតែមានៗណាស់អ៊ំហី?

ខៈ ចាំ!!គេមានចំការគេមានអីគេអ៊ីចឹងទៅប្រាក់ខែគេមិនច្រើនទេណាស់។

កៈចាំ!!អ៊ំរៀនពេលរៀនពេលហ្នឹងរៀននៅសាលាបឋមសិក្សាណាវិញ?

ខៈ នៅឈូងលៀបហ្នឹង!!

កៈ រៀននៅសាលាបឋមសិក្សាឈូងលៀបហ្នឹង?

ខៈចាំ!!

កៈអាកន្លែងអីគេ វឌ្ឍនៈហ្នឹងមែនសាលា?

ខៈ ហ្នឹងហើយឥឡូវគេដាក់វឌ្ឍនៈឈូងលៀប។

កៈហ្ហូពេលមុនតែឈូងលៀបទទេទេ?

ខៈ ឈូងលៀបទេ!!!

កៈ អ៊ំពេលរៀនហ្នឹងពេលក្មេងដែលអ៊ំកំពុងតែរៀនហ្នឹងក្តីស្រម៉ៃធំឡើងចង់ធ្វើអីគេវិញ?

ខៈ ចង់គ្រាន់តែថាបានចេះធ្វើការងារអីគេខ្លះទៅ តែដំណាក់កាលអ៊ីចឹងវាចប់ហាំ!!

កៈ ចុះអត់ទាន់ពេលមានសង្គ្រាមដែលស្រម៉ៃថាចង់ធ្វើអីគេទេអីអត់?

ខៈ ហ៊ីរឿងឪពុកម្តាយទីទាល់
បានសំរេចតែក្នុងចិត្តទេដូចថាព្រោះពីស្រុកភូមិមកម៉ែឪមិនចង់អោយកូនចេះដឹងទេព្រោះអីខ្លាចយើងសរសេរសំបុត្រសរសេរស្នាមអីផ្ញើប្រុសផ្ញើរឈ្មោលអីអញ្ចឹងណាស់!!

កៈ គ្រប់កន្លែងម៉ងគឺសុទ្ធតែអ៊ីចឹងម៉ង?

ខៈចាំ!!

កៈ ពេញស្រុកខ្មែរម៉ងអ៊ំហេ?

ខៈ ហើយបងខ្ញុំនៅរាល់ថ្ងៃនេះអត់ចេះអក្សរសោះ!!បានខ្ញុំទេ!

កៈដោយសារទស្សនៈមួយហ្នឹងអ៊ំណោះ?

ខៈ ហ្នឹងហើយ ហើយបងប្រុសចេះ មីមួយស្លាប់នោះក៏ចេះដែរ។

ក៖ចាំ!!

ខ៖ អត់តែបងស្រីញ៉ុមមួយទេ!!

ក៖ចាំដោយសារគាត់បងគេបង្អស់ឬក៏ម៉េច?

ខ៖ ចាំបងគេបង្អស់ មើលប្អូនមើលអីអញ្ចឹងទៅ ម៉ែឪអត់បានអោយនេះអីទេ ព្រោះអីមើលប្អូន!!ក៖ហ៊ុៗ!!

ខ៖តែខ្ញុំខូចជាងគេនៅពីទូច។

ក៖ អាងពៅគេអ៊ំហោ?

ខ៖ ហ្នឹងហើយ !!បានរៀនច្រើនជាងគេ។

ក៖ ហើយអ៊ំពេលនៅរៀនហ្នឹងមានមិត្តភក្តិដែលជិតស្និត ដែលដើរលេងជាមួយគ្នាអីទេ?

ខ៖ ហ៊ុ !!ពួកម៉ាក់ជិតស្និតកូនគេធ្វើពេទ្យនៅមុខនេះ។

ក៖ចាំ!!ឈ្មោះអីគេវិញពួកម៉ាក់អ៊ំ?

ខ៖ ឈ្មោះ សែ ខុនហ្នឹងហាំ!!!គេនេះគេនៅនេះគេមានគួរសមណាស់!!

ក៖ហ្ហ៎!!

ខ៖ក្រៅពីហ្នឹងពួកម៉ាក់ញ៉ុមនៅភូមិលើហ្នឹងមានប្តីមានអីទៅណាទៅណីអីអស់ហើយ នៅរៀនជាមួយគ្នាមួយកំនរហ្នឹងតែគេបែកដល់ពេលអ៊ីចឹងទៅគេបែក បែកអស់ទៅ!!

ក៖ចាំ!!

ខ៖ អាខ្លះនៅព្រែកឡុង ហ្នឹងគេនៅភ្នំពេញ នៅណានៅណីគេទៅមានប្តីមានអីអស់ហើយ។

ក៖ ហ៊ុអញ្ចឹងដោយសារ ភាគច្រើនជីវិតមនុស្សតែពេលនៅរៀនស្និតស្នាលជាមួយគ្នាអញ្ចឹង!!តែនៅរាប់អានគ្នាដល់ឥឡូវអ៊ំហោ?

ខ៖ បើជួបគ្នាស្គាល់គ្នារាប់អានគ្នាទាល់តែឥឡូវហ្នឹង។

ក៖ចាំ!!

ខ៖ តែដល់ឥឡូវគេបែកហ្នឹងគេក៏ទៅឆ្ងាយគេក៏ភ្លេចយើងរាប់ឆ្នាំហើយមីអូន។

ក៖ហ្នឹងហើយមានគ្រួសារមានអីរៀងៗខ្លួន!!

ខ៖ ហ្នឹងហើយមានចៅមានកូនមានអីទទឹមខ្លួនហើយ ទទឹមៗខ្លួនហើយកូនចៅ ឥឡូវទទឹមៗខ្លួនអស់ហើយគេនៅឆ្ងាយយូរៗមកម្តងគេភ្លេចយើងហ្នឹង!!។

ក៖អត់អាច!!

ខ៖ វាអត់អាចទំនាក់ទំនងគ្នាបានអើរបើថាយូរៗមកលេងគ្នាបងជួបគ្នាចេះតែស្គាល់ទៅណាស់ ស្គាល់គ្នាហ្នឹង គេទៅរាប់ឆ្នាំហើយ រាប់ឆ្នាំហើយមីអូន។

ក៖ចាំ!!

ខ៖គេក៏ភ្លេចយើង យើងក៏ភ្លេចគេដែរដូចប្រហាក់ប្រហែលក៏ថាក៏មានដែរ ខ្លាចច្រឡំ។

ក៖ចាំអញ្ចឹងអ៊ំពេលនៅកំពុងសិក្សាហ្នឹង
ការសិក្សាសប្បាយណាស់អ៊ំហេ?ពេលប្រលងអីវ៉ាន់សុចរិតអីអត់ពេលហ្នឹង?

ខ៖ ពេលប្រលងញ៉ុមនិយាយស្មោះត្រង់ញ៉ុមអត់ជាងគេខ្មែរ!!

ក៖ទៅអញ្ចឹងវិញ?

ខ៖ចាំ!!

ក៖ ខ្លាំងជាងគេគឺគណិតហេអ៊ីចឹង?

ខ៖ ខ្លាំងជាងគេតែងសេចក្តីបារាំង។

ក៖ហ្ហ៎អញ្ចឹងអ៊ំឥឡូវចេះបារាំងច្រើណាស់មែនទេ?

ខ៖ ព្រោះអីបារាំងវាអត់មានសូវរញ៉េរញ៉ៃដូចខ្មែរ។

ក៖ហ៊ឺៗ!!

ខ៖ កាលពេលហ្នឹងសង្គមថ្នាក់ទី៩គេរៀនបារាំងហើយណាស់!!

ក៖ចាំ!!

ខ៖ រៀនអី អុយ អីរហូតហើយ រៀនបំបែកតួអក្សរអីបានហើយរៀនតាំងពីថ្នាក់ទី៩ទៅ!!

ក៖ ហ្ហំអញ្ចឹងពីទី៩មកដល់ទី៧ហ្នឹងអ៊ំ!!

ខ៖ ទី៩ ទី៨ ទី៧ ៣ថ្នាក់ទេ សាលាថ្មតែ៣ថ្នាក់ទីណាស់!!

ក៖ចាំ!!

ខ៖ដល់តែប្រលងទៅព្រែកតូចថ្នាក់ទី៦ប្រលងពីថ្នាក់ទី៧ទៅថ្នាក់ទី៦ ទី៦ចូលទី៥។

ក៖ចាំ!!

ខ៖អញ្ចឹងទៅណាស់!!ចេះតែប្រលងទៅទៅ។

ក៖ ហ៊ឺអីចឹងអ៊ំពេលហ្នឹងខ្លាំងម៉ងអ៊ំហេ អើរភាសាបារាំង?

ខ៖ មានអី ខ្លាំងដែរប៉ុន្តែប្រុសៗក៏មិនខ្លាច ជើងខ្លាំងដែរ។

ក៖ អញ្ចឹងនិយាយបារាំងអីរាវម៉ងអ៊ំហេ ពេលហ្នឹង?

ខ៖ កាលហ្នឹងគេមិនសូវនិយាយទេ
បើគ្រូចូលទៅនិយាយទៅណាស់!!គាត់បង្រៀនទៅយើងនិយាយទៅ
ដាក់ក្តារពឹបៗទៅសរសេរតែងសេចក្តី
មើលតែគេហើយមួយសន្ទុះយើងសរសេរហើយដែរបើថាខ្មែរវីញញ៉ុមរកនឹករកអីសរសេរខុស
ចាំរចាំអីៗវាខ្វះវាពិបាកណាស់។

ក៖តែបើបារាំងស្រួលវិញ?

ខ៖ចាំវិញ!! ស្រួល មានអីអាណាមានអីអាណាមានឡឺមានតេអីទៀត។

ក៖ ញ៉ុមបារាំងចេះតែរាប់ អា បេ សេ ដល់ហ្សិនហ្នឹងតែអង់គ្លេសចេះទាំងអានចេះទាំងនិយាយ គេជនជាតិគេអីមកស្ដាប់បាន។

ខ៖ ឥឡូវរាងចំណាស់ជាងចាំបានហាគេនិយាយអីៗចាំបាន។

ក៖ហ្នឹងហើយ
ដូចនិយាយជាមួយអ៊ំអញ្ចឹងញ៉ុមអាចនិយាយភាសាអង់គ្លេសអីដែរបើសិនជាពាក្យណាជ្រៅៗអី អត់ដែលឮអត់ដែលដែរ!!

ខ៖អត់ទៅរួច!!

ក៖សួរគេវិញទៅថាអាហ្នឹងមានន័យថាយ៉ាងម៉េច អោយគេពន្យល់មកវិញហើយ!!

ខ៖ ចា៎អាហ្នឹងយើងត្រូវសិក្សារាល់ថ្ងៃ ចេះចាំហើយអូន។

ក៖ចា៎!!!

ខ៖ បើដូចខ្ញុំបោះចោលអស់រាប់ឆ្នាំហើយ!!

ក៖ចា៎ញ៉ុមបើសិនជាឥឡូវបើសិនជាញ៉ុមឈប់រៀននិយាយអង់គ្លេស
អត់មានអីទំនាក់ទំនងជាមួយជនជាតិគេសោះញ៉ុមក៏ភ្លេចអស់ដែរនេះហា!!

ខ៖ ហ្នឹងហើយ ដល់តែឧស្សាហ៍រំលឹកមេរៀន។

ក៖ចា៎!!

ខ៖ កុំអោយបាត់ការចងចាំ។

ក៖
ហ្នឹងហើយអញ្ចឹងអ៊ំសំរាប់ចូលដល់ការជីវិតអាពាហ៍ពិពាហ៍របស់អ៊ំវិញម្ដងអ៊ំរៀបការជាមួយស្វាមីគាត់ឈ្មោះអីគេដែរ?

ខ៖ យន់ ប៉ូច!!

ក៖ ឥឡូវគាត់ម៉េចដែរ?

ខ៖ គាត់ស្លាប់បាត់ហើយ។

ក៖ហ្នំគាត់ស្លាប់មូលហេតុអីគេដែរ?

ខ៖ គាត់ឈឺ!!

ក៖ ឈឺ!! គាត់ស្លាប់ប៉ុន្មានឆ្នាំហើយអ៊ំ?

ខ៖ ទេ!! គាត់ស្លាប់
ប៉ាង៉ែងស្លាប់ប៉ុន្មានឆ្នាំហើយមីអូន?(គាត់សួរកូនគាត់)ចូលយូរដែរហើយប៉ាហ្អែងនេះ!!

(កូន)៖ ចូល១០ឆ្នាំហើយ!!

ខ៖ ១០ឆ្នាំ!!

ក៖ ១០ឆ្នាំអញ្ចឹង២០០៨ហើយណោះអ៊ំហេ?

ខ៖ ចាំ!!

ក៖ គាត់ស្លាប់អាយុប៉ុន្មានដែរអ៊ំ?

ខ៖ តាកាលស្លាប់៥០ជាងហើយគាត់!!

ក៖ ហ្នំអីចឹងដោយសារជំងឺអ៊ំណោះ?

ខ៖ ចាំ!!!ដោយសារជំងឺ។

ក៖ អញ្ចឹងពិបាកដែរហ្នឹងអ៊ំ!!

ខ៖ហ៊ី!!

ក៖អញ្ចឹងហើយម៉េចជីវិតជាស្ត្រីមេម៉ាយដល់ពេលអត់ពីប្តីទៅម៉េចដែរអ៊ំម៉េចដែរ?

ខ៖ ហ៊ីធម្មតាមានប្តីក៏ប៉ុណ្ណឹងអត់ប្តីក៏ប៉ុណ្ណឹង!!

ក៖ម៉េចបាននិយាយអីចឹងវិញអ៊ំ?

ខះ ដូចថាជីវិតធ្លាប់ពិបាក!!
ពេលនៅក្មេងក៏ពិបាកពេលមានប្តីទៅក៏ពិបាកដូចប្តីអញ្ចឹងគេដើរទិញគោអញ្ចឹងទៅ
បន្ទុកនៅលើយើងហាំ!!ចងគោអញ្ចឹង
ហើយកូនទាំងអស់ទូចៗហ្នឹងផ្ញើរម្ដាយមួយភ្លេតហ្នឹងទៅដឹកគោយកមកផ្ទះអញ្ចឹងទៅណាស់
ដូចថាគាត់និយាយវាអត់ម៉ាប់អីទេណាស់ញ៉ុមពរយកទៅយកគោមកវិញ
ដល់ពេលគោផ្អើលដូចយើងប្រលែងមួយទៅណាស់យើងដាក់មួយធំលើស្មាទៅ។

កះហ៊ីៗ!!

ខះប្រវត្តិតស៊ូគឺថាតាំងពីធំដឹងក្តីមកគឺញ៉ុមពិបាកជាងគេ។

កះចាំ!!ខះ អត់មានស្រណុក ពីបាកជាងគេគឺពិបាកកូន។

កះ តែប្តីអីហ្នឹងគាត់សមប្រកបដែរតើអុំហី?

ខះ ប្តីមានអីគេមិនដែលវ៉ៃមិនដែលនេះយើងទេ!!តែគាត់ថាគាត់រកគាត់រកហើយ តែយើង
យើងស្រីប្រុសតែយើង។

កះ គាត់រករកដែរ ប៉ុន្តែអុំត្រូវរ៉ាប់រងដែរ?

ខះ រ៉ាប់រងយើងចង់ចិញ្ចឹមជ្រូកយើងទៅរកចំណី។

កះចាំ!!

ខះ ដាក់កូនចោលអុីចឹងគេបានរកត្រីអញ្ចឹងមកយកចង់បានផ្ញើរ យើងផ្ញើរទៅ
ផ្ញើអីខ្លួនយើងគាត់អ្នករកយើងអ្នកទុកអ្នកដាក់អីអុីចឹងទៅណាស់!!!

កះ អញ្ចឹងគាត់ល្អដែរហ្នឹងអុីចឹង?

ខះគាត់ល្អ តែគ្រាន់តែខ្ញុំពិបាករហូតអុីចឹងទៅណាស់!!

កះ ដោយសារអុំសំរេចចិត្តចង់ធ្វើមួយហ្នឹងដោយខ្លួនឯង!!

ខះ ហ្នឹងហើយ បើយើងមិនធ្វើគេរកមកហើយម៉េចកើត ធ្វើប្រអក ធ្វើប្រហុក
ចង់ផ្ញើរអីតែយើងទៅណាស់ មានកូនទូចកូនធំអីពិបាកតែយើងហ្នឹង ។

កះចាំ!!

ខះមានទឹកកើយណាបានមានតែទៅដងនៅទន្លេ។

កះឆ្ងាយដែរហ្នឹងអ៊ំ?

ខះ ចាំ!ដងទន្លេប្រវែងហ្នឹងមកហ្នឹងរែកចង់ហាមាត់ហាំ!!

កះហ្នឹងហើយ។

ខះ ពោះធំញ៉ុមរែកចង់ជ្រុះកូនហ្នំ!!

កះ ងាប់ហើយអ៊ំរែកទឹកពេលពោះធំម៉េចទេ!!

ខះ
ហ្វប្តីទៅរកស៊ីជួញគោបាត់មានតែ១ខែទៅ២ខែទៅ៣ខែនេះមីនេះចេះដើរតេសតាសអត់ស្គាល់
ឪវាផង ទៅបាត់យូរ!!

កះចាំ!!

ខះ ហើយញ៉ុមវាកំសត់ទៅហើយ ថាវាកំសត់អ៊ីចឹងម៉ង!!

កះ ចាំ!!តែអ៊ំភាគច្រើនគេនិយាយថាភាគច្រើនអ្នកជួញគោមានប្រពន្ធមានអី
តែគាត់អត់ទេអ៊ំហី?

ខះ មានរឿងធម្មតាទេ ញ៉ុមអត់មានការយកចិត្តទុកដាក់ផង
តែគាត់យកលុយយកមកអោយចាយហ្នឹង អត់មានបញ្ហា ។

កះ អ់តមានអីទេហេ?

ខះ ចាំ!!

កះ ភាគច្រើនញ៉ុមសំភាសន៍អ៊ំណានោះនៅកំពង់ចាម
អ៊ំណានោះប្តីគាត់ជួញគោដែរនិយាយពីថាជំពាក់គេនឹងមាន មានស្រី។

ខះ ញ៉ុមអត់ទេ បើគាត់អញ្ជឹងគាត់ទៅរកមកសងគេអ៊ីចឹងទៅណាស់!!

កៈចាំ!!

ខៈ រកទៅយកមកសងសង ហើយបានយកមកស៊ីទៅណាស់!!

កៈ ចាំ!!បើសិនជាធ្វើត្រូវផ្លូវមានអីសល់មានណាស់អ៊ំ!!

ខៈ ពេលខែធ្វើដាក់លបដាក់ទ្រូអាហ្នឹងបានសល់!!

កៈចាំ!!

ខៈ បានមាសបានអីពាក់អ៊ីចឹងទៅណាស់។

កៈហ៊ឺៗ!!

ខៈ ដល់ពេលគាត់ឈឺយើងអត់ត្រូវតែលក់ !!

កៈចាំ!!

ខៈ មួយខែដូចថាមួយអាទិត្យ១០០០០០ ១០០០០០ពីហ្នឹងថ្លៃដែរណាស់ ១០០០០០ ២០០០០០អីយើងចេះតែបិចហើយ!!បានប៉ុន្មានធ្វើបិចទៅអស់។

កៈចាំ!!

ខៈ ដល់គាត់ស្លាប់យើងអស់ដែរអត់មានសល់អីទេ!!

កៈ រកទុកពេលសំរាប់ឈឺ។

ខៈ រកទុកសំរាប់គេឈឺ!

កៈ ចាំអ៊ីចឹងអ៊ំសំរាប់ស្វាមីរបស់អ៊ំអ៊ំរៀបការជាមួយគាត់នៅឆ្នាំណាវិញ?

ខៈ ខ្ញុំហោ!!ខ្ញុំរៀបការប្រហែលឆ្នាំ៧៤(១៩៧៤)អីហ្នឹង!

កៈ អ៊ីចឹងមុនប៉ុល ពត?

ខៈ ចាំ!!

កៈ អ៊ីចឹងឆ្នាំ១៩៧៤
អ៊ីចឹងអ៊ំការស្រលាញ់គ្នាជាមួយស្វាមីហ្នឹងហាំដំបូងឡើយម៉ែឪរៀបចំផ្សំផ្គុំអោយឬក៏ស្រលាញ់គ្នាដោយចិត្តឯងឃើញស្រលាញ់គ្នា?

ខៈ អត់ទេម៉ែឪនេះហ្នឹង ដល់ពេលយើងរត់ទៅអត់បានការ យើងទៅការនៅស្រុកគេ។

កៈហ្ហ៊ូ!!

ខៈ ការយើងរត់ទៅហាំ!!

កៈ គាត់អ្នកស្រុកមកពីណាវិញអ៊ំប្តី?

ខៈ ជាមួយគ្នានៅភូមិជាមួយគ្នាហ្នឹង!!!!

កៈនៅភូមិព្រែកថីហ្នឹងតែមួយទេអ៊ីចឹង?

ខៈ ចាំ!!មួយមុខមួយក្រោយអ៊ីចឹងដូចមីអូនផ្ទះនៅមុខអញ្ចឹងញ៉ុមនៅក្រោយ!!
ញ៉ុមនៅមុខគាត់នៅក្រោយ។

កៈចាំ!!អ៊ីចឹងស្គាល់គ្នាតាំងពីក្មេងមកដែរហ្នឹងអ៊ីចឹង?

ខៈ ចាំ!!

កៈ អ៊ីចឹងក៏អាចយល់ចិត្តគ្នាបានខ្លះៗដែរអ៊ំណោះ?

ខៈចាំ!!

កៈ ហ្នឹងហើយ ម៉េចដែរអ៊ំថ្ងៃការភ័យទេ?

ខៈ ភ័យអរភ័យអរ។

កៈ ដល់ពេលការហើយអ៊ំមានកូនប៉ុន្មាននាក់វិញជាមួយស្វាមី?

ខៈ ខ្ញុំដល់៧ឆ្នាំហ្ហ៊ូ!!បែកអាពតហើយមីអូនអត់មានកូនទេ!!

កៈ ហេងហើយអ៊ីចឹង!!

ខ៖ សុំកូនធម៌គេដូចថាគេ គេមើលក្មេងនៅភ្នំពេញអីចឹងគេជំលៀសមកហាំ!!

ក៖ហ៊ឺៗ!!

ខ៖ ហើយពួកឃុំហ្នឹង អ្នកបំរើគេ អ្នកបំរើៗគេគេដកទុកហាំ!!
ខ្ញុំនឹងគ៏ទៅប្រជុំនៅមន្ទីរឃុំសិត្សហ្នឹងហាំ!!

ក៖ចាំ!!

ខ៖ ហើយដល់គណៈឃុំហ្នឹងថាអើរមិត្តនារី ?ញ៉ុមថាចា!! អត់កូនអត់ចៅដូបារទៅ
ញ៉ុមថាអត់ទេ!! ដូរញ៉ុមមក ?ញ៉ុមថាអត់ទេ អញ្ជឹងបងឯងយកកូនមួយទៅ
!!ដល់នេះគេអោយធំៗដូចកូនញ៉ុមអញ្ជឹងណាស់!!ញ៉ុមថាអត់យកទេ
ហើយប្ដីញ៉ុមក៏នៅក្មេងដែរ
ហើយយើងខ្លាចសីលធម៌ហ្នឹងវាងាប់ហា!!ជំនាន់អាពតហាំ!!តែយើងខូចសីលធម៌ហ្នឹងគេយក
យើងទៅសម្លាប់ចោល។

ក៖ចាំ!!

ខ៖ ហើយញ៉ុមថាអត់យកទេ ដល់ហើយគេអោយក្មេងស្រីអាយុ១២ឆ្នាំប៉ុណ្ណឹង ខ្ញុំក៏យកមក
យកមមកមកនៅជាមួយខ្ញុំដំបូង មុនដំបូងគ្នាអត់ហ៊ានហៅម៉ាក់ប៉ាអីអញ្ជឹងទេណាស់។

ក៖ចា!!

ខ៖ ដល់ពេលបានមួយខែហៅយើងម៉ាក់ហៅប៉ាវាហ្នឹងអាប៉ា ហៅញ៉ុមម៉ែ !!

ក៖ចាំ!!

ខ៖ ដល់ហើយដល់យូរបាន២ ៣ឆ្នាំបានមានមីនេះមួយហិ បាន៧ឆ្នាំមានមីនេះមួយ!!

ក៖ ហ្វាំហោងហើយអីចឹង!!

ខ៖ ហោង!!

ក៖ គិតថាអត់ហើយទេហី?

ខ៖ អត់ហើយ!! ដល់ពេលបាន៧ឆ្នាំបានមីនេះមួយ។

ក៖ចាំ!!

ខ៖ បានមកវាបន្ទាប់មួយទៀតងាប់
ងាប់ទៅបានមីមួយនៅក្រោយនេះមួយបានបន្ទាប់អាមួយពៅនោះមួយបានប្រុស២ស្រី៣។

ក៖ចាំ!!

ខ៖ តែប្រុសនោះងាប់បាត់ហើយបន្ទាប់មីនេះហាំ!!

ក៖ អ៊ីចឹងបង អ្នកមីងបងគេណោះ?(កូនស្រីគាត់ច្បងនៅក្បែរនោះ)

ខ៖ចាំ!!

ក៖ចាំ!!អ៊ីចឹងអ៊ំសំរាប់កូនអ៊ំ ប៉ុន្មាន៥នាក់ហេ?

ខ៖ ៥នាក់។

ក៖អ៊ំទាំងស្លាប់ទាំងរស់ទាំង៥នាក់គាត់ឈ្មោះអីគេខ្លះអ៊ំប្រាប់មើល?

ខ៖ មួយនេះប៉ូច សំណាង!!

ក៖ចាំ!!

ខ៖ មួយទៀត ប៉ូច ចាន់និត អាស្លាប់ទៅហាំ!!

ក៖ចាំ!!

ខ៖ នោះប៉ូច ចំណាប់ ប៉ូច ចំណាន ប៉ូច ភិរុត!!

ក៖ចាំ!!

ខ៖តែប៉ុណ្ណឹងនាក់ទេ!!

ក៖ ចុះគាត់មិនមែនកូនរបស់អ៊ំណាហី?

ខ៖ ណា?

ក៖ បងស្រី?ចៅឬក៏អី?

ខ៖ កូនស្រីនេះ?

ក៖ចាំ!!

ខ៖កូនតើ!!

ក៖កូនហេ?

ខ៖ចាំ!!

ក៖ឈ្មោះអីគេ?

ខ៖ ប៉ូច ចំណាន!!

ក៖ ចំណានហេ?

ខ៖ ចាំ!!ចំណាប់សរជាហ្នឹង។

ក៖
ចាំអីចឹងកូនអ៊ំរៀងក្មេងៗដែរ។អីចឹងអ៊ំសំរាប់កូនទាំង៥នាក់ហ្នឹងអ៊ំមានអោយគាត់ទៅរៀនទាំងអស់គ្នាអត់?

ខ៖ សុទ្ធតែរៀនតើពួកអស់ហ្នឹង!!

ក៖ ចាំរៀនបានថ្នាក់ខ្ពស់ៗដែរហ្នឹងអ៊ំហេ?

ខ៖ ទេដឹងថ្នាក់ទីប៉ុន្មានទេមីអស់ហ្នឹងនេះ!!

(កូន)៖ញ៉ុមថ្នាក់ទី៨ទី៨ឈប់។

ក៖ បានច្រើនដែរហ្នឹងមីងណោះ!!

ខ៖ មីងនោះចូលប្រលងថ្នាក់ទី១២ហ្នំ!!ឈប់!!

កះហុឺៗ!!

ខះ ឪពុកវាឈឺ!

កះ ដល់ទី១២ហើយឈប់?

ខះទាល់ដៃទាល់ជើង។

កះ ហើយក៏នេះម្លែះ!!១២ហើយ។

ខះ ហើយអាស្លាប់ទៅប្រលងចូលសកលវិទ្យាល័យអត់ជាប់។

កះចាំ!!

ខះមួយឆ្នាំហើយ ញ៉ុមថាកូនឯងរៀនទៀតទៅ វាថាខ្ជិលណាស់ ខ្មាស់គេ
!រៀនមួយឆ្នាំទៀតទៅកូន អង្វរកូនហាំ!!

កះចាំ!!

ខះ រៀនមួយឆ្នាំទៀតទៅ គ្រាន់ធ្លាក់ភ្លាម ដាក់ឌីម៉ង់ដាក់អីទៅធ្វើការអត់បាន
សិយទាំងអស់កូនអើយ!!

កះ ហើយគាត់ស្លាប់ថីអ៊ីចឹង?

ខះ គ្រោះថ្នាក់ចរាចរណ៍។

កះ អើយអ៊ំហើយអ៊ំ!!

ខះ អាយុ២៦ឆ្នាំស្លាប់ហ្នឹងហាកូន កំពុងពេញស្រលាញ់!!

កះ ហើយអត់ទាន់ការអត់ទាន់អីទាំងអស់អ៊ំ?

ខះ អត់ទាន់។

កះ ចាំ!!ស្លាប់ពេលនៅនៅលីវ!!ហើយម៉េចដែរអ៊ំគ្រោះថ្នាក់ចរាចរណ៍ពិបាកណាស់អ៊ំហេ?

ខះ អើរដូច!!

កះ ស្លាប់នៅនឹងកន្លែងហីអី?

ខះ អត់ទេយកមកពេទ្យកាល់ម៉ែត អូនមើលទៅវា សួរវាមើលអត់មានអីទេ
ដូចយើងដួលកង់អ៊ីចឹង គ្រាន់តែថាវាបាក់សរសៃករ។

កះ ហ្ហ៎ចប់ហើយនឹងហ្ហ៎!!

ខះ ហើយដល់ពេលលើកក្ដារមឈូសបានឃើញហើម កករឡើងធំ
សាច់ឈាមវាអត់មានអាលោតអាលួយអីហ្នឹងគេទេ ស្អាតថៃស!!

កះ ឡានបុកឬក៏អំ?

ខះ អើរផ្លូវកោង អាឡានក៏មកអាយើងក៏មក
វាជៀសឡានហ៎!!ទៅធ្លាក់ជង្ហុកយើងទូលក្រសាំងអញ្ចឹងហ៎ ប្រឡាយអ៊ីចឹងហ៎!!

កះចា៎!!

ខះ ទៅបុកដូចអាជីគេចាក់អ៊ីចឹងហ៎!!

កះហ៊ឺៗ!

ខះឮតែគេថាតែញ៉ុមអត់ទៅផ្ទាល់ទេ។

កះ ប៉ុន្មានឆ្នាំហើយកូនស្លាប់?

ខះ ហេអាអូនស្លាប់មុនប៉ាវាទៀតហ្ហ៎!!

កះ ស្រណោះណាស់អំអើយកូនកំពុងពេញស្រលាញ់!!

ខះហ៊ឺកំពុងពេញហើយ តាំងពីហ្នឹងមកធ្លាក់ខ្លួនរហូតញ៉ុមស្គម កាលមុនញ៉ុមមានសាច់តើ!!

កះចា៎!!

ខះ ដល់អ៊ីចឹងស្គមរហូតកែលែងឡើងហើយ!!

កះ ពីបាកចិត្តរឿងកូនស្លាប់អីផង!!

ខ៖
កូនស្លាប់មកអាប្តីហ្នឹងស្លាប់ទៀតហើយណាមួយយើងចិញ្ចឹមពូកអស់នេះពិបាកវេទនាចេះតែត ស៊ូអ៊ីចឹងទៅណាស់។

ក៖ចាំអ៊ិចឹងអ៊ំនិយាយពីជីវិតរបស់អ៊ំតាំងពីតូចរហូតដល់ធំអំពីប្រវត្តិសង្គ្រាមវិញមើល !!អ៊ីចឹងដំបូងអ៊ំទាន់ជំនាន់ឥស្សរដែរតើអ៊ំហេ?

ខ៖ទាន់ អត់ទាន់ឥស្សរទេទាន់អាដេញ!!

ក៖ លន់ នល់ ហើយប៉ុល ពត!

ខ៖ លន់ នល់ ហើយប៉ុល ពត!!

ក៖ អ៊ីចឹងអ៊ំមានដែលឮអីគេខ្លះពីជំនាន់ឥស្សរអីអត់?

ខ៖ លឺតែម៉ែឪនិយាយហ្នឹង !!

ក៖ ថាម៉េចទៅអ៊ំ?

ខ៖ ថាជំនាន់បារាំងអីថាគេបាញ់នៅព្រៃកចីនេះ!!
កាលមុនគេដាក់ស្ពានព្រៃកចីហ្នឹងពូកចីហ្នឹងគេនៅហ្នឹងហាំ!!នៅស្ពានព្រៃកចីហ្នឹង
តែប៉ុណ្ណឹងទេ!!បាញ់បារាំងហ្នឹង
បានសម្តេចតាគាត់នយោបាយអ៊ីចឹងទៅក៏បារាំងហ្នឹងទៅស្រុកវិញទៅក៏វាសាន្តគ្រានគ្នាអ៊ីចឹង ទៅរហូតទៅ!!

ក៖ ក៏ចប់អាហ្នឹងទៅ!!

ខ៖ ចប់សង្គ្រាមហ្នឹងទៅ!!មួយវគ្គទៅ!!

ក៖ ម៉ាអាណានិគម។

ខ៖ ម៉ាអាណានិគមហ្នឹង ហើយដល់លន់ នល់
ធ្វើរដ្ឋប្រហារហ្នឹងបានគេនាំទាហាននាំអីហ្នឹងប៉ុល
ពតនាំគ្នាចូលព្រៃចូលអីហ្នឹងបាញ់គ្នាមួយសារទៀហ្នឹង!!

កះ អ៊ំនិយាយពីពេលអាពេលទំលាក់គ្រាប់មើលម៉េចដែរ?

ខះ ជំនាន់ទំលាក់គ្រាប់ណាស់មីអូនបើអ៊ំដាំបាយហាំ អត់ហ៊ានដាំទេក្រោកពីយប់អត់អោយកប៉ាល់ហោះឃើញផ្សែងទេខ្លាចវាឃើញផ្សែងវាបាញ់ពង្សពីតាខ្មៅមកជូនកាលកប៉ាល់ហោះហ្នឹងទៅទន្លេមេគង្គពីរ យើងនេះពីរទំលាក់សុទ្ធតែអាគ្រាប់បូម។

កះ ម៉េចទៅអាគ្រាប់បូមអ៊ំ?

ខះ គ្រាប់បូម ហ្អែងដែលឃើញស្រះទេ?

កះចាំចាំ!!

ខះ
ដូចស្រះដូចគេជីកអីចឹងណាស់!!បូមហ្នឹងដូចថាមួយទីធ្លាកូនញ៉ុមហ្នឹងបូមហ្នឹងគេជីកហែកដីសងខាងម៉ង នៅអន្លង់ជ្រៅម៉ង!!ម៉ាម៉ាខ្មោលម៉ង។

កះអូយ!!

ខះ មួយឬស្សីយើងហ្នឹងម៉ងជ្រៅម៉ង!!

កះហ៊ឺៗ!!

ខះទៅមើលស្ទឹងហ្វ៊ូយកទៅណាស់អស់អន្លង់!!

កះអើយខ្លាចណាស់អ៊ំ!!ហើយដល់ពេលម៉េចទៀតទៅអ៊ំ?ដល់ពេលវាផ្លោងពីតាខ្មៅអីហ្នឹងមក?

ខះ យើងចេះតែនេះទៅអាណាត្រូវងាប់ទៅ ត្រូវគោក៏ងាប់ទៅ តាមព្រេងវាសនាអីចឹងទៅ។

កះតែគោលបំណងគឺបាញ់ពួកប៉ុល ពតទេអីចឹងណោះ?

ខះ បាញ់ប៉ុល ពតទេ តែវាបាញ់មកចូលក្នុងភូមិ។

កះ ប្រហែលជាគិតថាប៉ុល ពតវានៅជាមួយអ្នកភូមិហោ?

ខ៖ នៅជាមួយអ្នកភូមិ!!អូនកាលញ៉ុមមកនៅភូមិព្រែកថីនេះកន្លែងមន្ទីរឃុំហ្នឹង
ញ៉ុមនៅខាងត្បូងមន្ទីរឃុំហ្នឹងបន្តិចពួកទាហានចុះមកច្រែមច្រុំ
ចុះនៅកន្លែងកុមារអរុណរះហ្នឹង។

ក៖ចាំ!!

ខ៖ ចុះពីហ្នឹងមកវាទៅសំរាកនៅហ្នឹងហើយ!!
ហើយអាស្លាបកាត់វានៅងឹងៗអាដូចត្រីតាហោរហ្នឹងបាញ់មួយយប់ទាល់ទាល់ភ្លឺ
តឹតៗៗៗៗៗៗវាបាញ់ឆត្រ័មួយអញ្ចឹងទៅភ្លឺ
ភ្លឺអីចឹងវាបាញ់តាមខ្សែទន្លេហ្នឹងទៅរហូតទៅណាស់។

ក៖ហ៊ឺ!!អ៊ំពេលហ្នឹងមិនដឹងភ័យយ៉ាងណាទៅអ៊ំ អ៊ំពេលហ្នឹងទៅនៅណាវិញអ៊ំ?

ខ៖ ញ៉ុមនៅនឹងគល់ស្ពានព្រែកថីហ្នឹង!!

ក៖ នៅនឹងស្ពាន?

ខ៖ នៅខាងត្បូងហ្នឹង!!

ក៖ តែមានផ្ទះមានអីដែរតើហី?

ខ៖ មានផ្ទះយើងតូចៗ ផ្ទះមិនមែនធ្វើអញ្ចឹងហាមហឿនមានឈើអីចឹងគ្រាន់បើ
គ្រាន់តែបាំងប៉ាងអាសី បាំងគ្រាន់ពទ្ធ័ជ្រុងនៅតាមគ្រួសារអីចឹងណាស់!!

ក៖ហ៊ឺៗ!!

ខ៖ មួយគ្រួសារមួយគ្រួសារអីចឹងរហូតទៅ។

ក៖ចាំ!!

ខ៖ ហើយពេលណាគេហ្វ៉ូគេជំលៀសទៅនៅព្រែកស្ទេហ៍ព្រែកស្នងទៅទៅ
មានគោមានរទេះដឹកកូនដឹកចៅទៅ ហ្វ៉ូពេលល្ងាចហ្នឹង
យើងអត់កូនគេអត់អោយទៅទេយើងនៅដេកនៅហ្នឹងជាមួយយោធា។

ក ៖ជាមួយពួកយោធា ខាងប៉ុល ពតឬមួយក៏ខាងលន់ នល់?

ខ៖ ខ្មែរៗយើងហ្នឹង។

ក៖ ដឹងហើយលន់ នល់?

ខ៖ ពួកយោធាហ្នឹង យួនគេថាយួនៗ!!

ក៖ហ្ហ៎!!

ខ៖ ពួកទាហានផ្សេងទេ។

ក៖ យោធាហ្នឹងពួកយួនវិញ?

ខ៖ ស្លៀកកាទឹបៗៗអញ្ចឹងនោះ!!

ក៖ ហ្ហ៎អញ្ចឹងចូលដល់ពេលជំនាន់លន់ នល់ហ្នឹងមានយួនមកដែរអ៊ំហេ?

ខ៖ ហ្នឹងហើយ យើងជំលៀសមកគេមានយួនមានអីមកពាក់កាទឹបៗៗអីចឹងណាស់!!

ក៖ហ៊ឺៗ!!

ខ៖
ដល់ពេលគេដកទៅយើងនៅប្រជាជនដដែលទៅដល់ពេលនេះមកគេដឹងមកគេវ៉ៃដេញៗៗម
កអញ្ចឹងយើងរត់ទៅនៅព្រៃករុនក្នុងណោះ!!

ក៖ហ៊ឺៗ!!

ខ៖ អាហ្នឹងពួកអាពតបែកហើយនៅព្រៃករុនក្នុងហ្នឹងគេនិយាយគ្នាស្អីៗ
យើងដូចគ្មានចាប់អារម្មណ៍នឹកឃើញថាបែកអីអញ្ចឹងទៅណាស់!!ក៏ខ្ញុំហ្នឹងក៏ចេះចាំមើលផ្លូវកូន
ហ្នឹងនៅព្រៃកថីហ្នឹងឆេះស្ពានឆេះអីខ្ទេចខ្ទីអស់ហើយ
ញ៉ុមនៅចាំមើលកូនចិញ្ចឹមហ្នឹងរហូតណោះដល់ច្រៃមច្រំហ្ហ៎
ហើយវានៅចាំស្រូវចាំអីហ្នឹងក៏ញ៉ុមនៅចាំបាត់ចាំបាត់ម្លឹងៗយូរម្ល៉េះចាំមើលកូនហាំ!!ខ្ញុំទម្ងន់មី
នេះ៧ខែ រត់ពីហ្នឹងទៅនៅតាខ្មៅហ្ហ៎!!

ក៖ចាំ!!

ខ៖ លើវត្តព្រៃកសំរោងទៀត!!

ក៖ហ៊ឺៗ!!

ខ៖ អាហ្នឹងយួនខ្លះ យួនហាំ!!

ក៖ចាំ!!

ខ៖យួននៅអញ្ចឹងជាមួយទាហានយើងពេលហ្នឹង!!!

ក៖ ហើយម៉េចពេលហ្នឹងបានមានយួនមកនៅខ្មែរវិញ?

ខ៖ គេរំដោះជួយរំដោះ ដេញយួនចេញពីស្រុកអញ្ចឹងទៅណាស់ ហាដេញអាដេញពួកប៉ុល ពតទៅអញ្ចឹងទៅអញ្ចឹងអស់ទៅ!!

ក៖ អ៊ីចឹងយួនមកជួយដេញប៉ុល ពតវិញ?

ខ៖ ចាំ!!!ដេញអ៊ីចឹងដល់ពេលយួនហ្នឹងវាទៅស្រុកវាធ្វើបុណ្យធ្វើអី ប៉ុល ពតឡើងមួយសារទៀតសម្លាប់ខ្មែរអស់មិនស្មើរទេ!!
ខ្មែរៗដូចថាទៅរស់នៅកន្លែងវាលរង់សាលារៀនវត្តទួលក្រសាំងហ្នឹងមីអូន សាលារៀនគេធ្វើឃ្លាំងធំណាស់គេដាក់ស្រូវ ហើយក្តារសុទ្ធតែអស់ទាស់ហើយ ក្តារសុទ្ធតែបណ្តោយ២០
៣០ម៉ែត្រអញ្ចឹតងមួយសន្ទបមួយសន្ទបហាំ!!!!មួយឃ្លាំងហ្នឹងធំមែនទែន ធំមែនទែនកន្លែងហ្នឹង!!

ក៖ ចាំ!!អ៊ំពេលនៅជំនាន់លន់
នល់ហ្នឹងគេល្បីថាអារឿងសម្លាប់យួនអណ្តែតទឹកនោះអ៊ំដែលឃើញទេ?

ខ៖ គេសម្លាប់នេះលើម្តុំអ៊ំក្លូរនេះ!!

ក៖ ម៉េចដែរទៅអ៊ំមានឃើញ គេបណ្តែត?

ខ៖ អត់ឃើញទេ!!អត់ឃើញផ្ទាល់ភ្នែក!!

ក៖ អត់ឃើញផ្ទាល់ភ្នែកតែលឺគេនិយាយហោ?

ខ៖ លឺគេនិយាយថាបាញ់នៅផ្សារយើងឈូងលៀបនេះ!!!គេមកបាញ់នឹងតើ!!

ក៖ហ៊ឺៗ!!

ខ៖គេសម្លាប់គាត់ហ្នឹងចាស់ជាងខ្ញុំគាត់ធាត់លក់បបរ។

ក៖យួនហ្នឹងហេ?

ខ៖ ចាំ!!កូនហ្នឹងទៅធ្វើការអាត្រើសៗជាងនេះអាធំត្រើសៗហ្នឹងនៅជាមួយគាត់
នឹងងាប់អស់២នាក់នៅសល់តែម្នាក់ទេ!!ហើយគាត់ហ្នឹងក៏ស្លាប់ដែរ
គាត់លក់បបរនៅផ្សារហ្នឹងហាំ!!!

ក៖ចាំ!!គេកាប់អាហ្នឹងលឺថាគេបាញ់សម្លាប់ចោលបណ្តែតទឹកទៅយួនវិញម៉ងហាំអំណាស់!!

ខ៖ ចាំ!!អាខ្លះរត់ឆ្លងទឹកគេបាញ់ពីក្រោយនោះងាប់ទៅ!!

ក៖ ម៉េចទៅអំអាហ្នឹង?

ខ៖ ហើយដុតផ្ទះឆេះ
ខ្ញុំអត់ហ៊ានទៅឯណាទេនៅក្នុងផ្ទះហ្នឹងកូនខ្ញីអត់ហ៊ានទៅណាទេខ្លាចគេសម្លាប់!!ខ្លាចគេបាញ់
គេថាយួនមិនបានអុជចង្កៀងខ្មែរអោយអុជចង្កៀងហើយញ៉ុមមិនភ័យខ្មែរយើងអុជចង្កៀងកាទឹ
បមានភ្លើងមកពីណា។

ក៖ហ៊ឺៗ!!

ខ៖
អាណាយួនៗគ្នាមានហ៊ានអុជណាខ្លះគេគេចខ្លួនចូលមកផ្ទះយើងស្នាក់នៅអីចឹងទៅនៅជីតគ្នា
ហាំ!!!ចេះតែគ្នាមកនៅជ្រកកោនអញ្ចឹងទៅមីអូន!!

ក៖ហ៊ឺៗ!!

ខ៖ ដល់ហើយគ្នាទៅអញ្ចឹងហំ គ្នាភ័យខ្លួនអញ្ចឹងហំ
ទៅនៅភ្នំពេញវិញក៏ទៅទៅណាស់!!គ្នាទៅនៅស្រុកក៏ទៅទៅ។

ក៖ហើយមិនព្រមទៅប្រទេសខ្លួនឯងវិញទៅអត់ទេ!!!!

ខ៖ ខ្លះអ្នករស់ហ្នឹងទៅក្រោមតើ!!

ក៖ហ៊ឺៗ!!

ខ៖បប្អូលញ៉ុមថាបើមានអាសន្នអីទៅក្រោមទៅគាត់នៅចាំក្រោម
ហើយញ៉ុមទៅរកឯណាលោកអើយលោកលោក ខ្ជិលណាស់!!

ក៖ហ្នឹងហើយ ពួកវា!!

ខ៖ ពិបាកដែរ។

ក៖ហ្នឹងហើយមិនមែនទៅស្រួលអីអំអើយ!!

ខ៖ មីអូនអើយ ស្រករឥឡូវដូចជំនាន់លន់ នល់ គេចាប់ទាហានអត់សល់ទេ!!

ក៖ចាំ!!

ខ៖លន់ នល់ ចំបក់វ៉ៃព្រែកតូចហាំឡានហាំចុះទៅ៦ឡានពេញៗតែមកវិញតែ២ឡានទេ!!

ក៖ ហ៊ឺ!!បាញ់គ្នាងាប់អស់រលីងម៉ងហោ?

ខ៖ បាញ់គ្នាអស់មីអូន
បើថាចូកសពដាក់ឡានវិញហូរតាមផ្លូវក្លិន!!ហើយញ៉ុមធ្វើបាយអោយហើយអីចឹង
ហើយទាហានក្មេងៗពួក១៧ ១៨
ហ្នឹងនិយាយថាបងស្រីអើយញ៉ុមទៅហើយមិនដឹងខ្ញុំងាប់មិនដឹងរស់ទេ
ញ៉ុមថាអូនអើយកុំនិយាយអីចឹង
មានអាសន្នអីអូនឯងនឹកគុណមាតាបិតាអញ្ចឹងទៅណាស់!!បានជួយយើងអញ្ចឹងហើយ!!ហ៊ឺមិន
ដឹងអីទេបងអើយ!!ទៅវិញមានដឹងមកណា!!! ទៅអស់ៗទៅ១៧ ១៨បង្ហាត់ត្រឹមតែ៧ថ្ងៃទេ។

ក៖ វាអោយចេញបាញ់ម៉ង?

ខ៖ ដឹងតែអោយចេញបាញ់អោយតែយើងចេះកៃ ចេះកៃ
មានចេះយុទ្ធសាស្ត្រណាខ្លាំងណាដូចឥឡូវហ្នឹង គេហ្វឹកហ្វឺនលោតឆត្រ័លោតអី
ហ្វឹកហ្វឺនទាល់តែមែនទែនគេបញ្ជូនទៅស្រុកគេណោះ!!!!

ក៖ចាំ!!

ខ៖ ទៅចិន!

ក៖ វៀតណាម។

ខ៖ អាល្លឺម៉ង់ វៀតណាមអី ប្រទេសអីណា!!គេ នេះអត់ទេ!!

ក៖ អ៊ំឆ្លងកាត់អស់រលីងហើយ!!ឥឡូវចូលប៉ុល ពតវិញម្តងមើលអ៊ំអាពេលថ្ងៃចប់ គេដូចថាលន់នល់ចាញ់សង្គ្រាមប៉ុល ពតវិញនោះម៉េចទៅអ៊ំអាពេលចូលថ្ងៃដំបូងហាំ??

ខ៖ ប៉ុល ពតចូលហោ?

ក៖ចាំ!!!

ខ៖ អើយប៉ុល ពតចូល
អើរខ្ញុំនៅមាត់ព្រែកថីខាងណោះដល់ពេលជំលៀសមកអញ្ចឹងយូរៗយើងទៅចំការហាំ!!
ទៅចំការចាំមើលជំនាំជំណោចចាំមើលរបស់ដៃរធ្វើបានហ្នឹងចាំទៅបេះយកមកលក់យកមកដូរអីណាស់ អត់បានទេ!!

ក៖ វាអត់អោយបេះម៉ង?

ខ៖ វាមិនអោយបេះ ហើយយើងខ្លាច បើទាហានចូលទៅដល់ហ្នឹងយើងបេះអីបេះទៅ។

ក៖ចាំ!!

ខ៖ ហើយដល់ពេលទាហានមកយើងមក
មកតាមទាហានមកមុនទាហានមកខ្លាចជួបគ្នាបាញ់គ្នា។

ក៖ហ៊ឺ!!

ខ៖ ពិបាកណាស់។

ក៖ អាហ្នឹងពេលថ្ងៃដំបូង!ហើយវាមានចាប់អ៊ំជំលៀសទៅណាទេអ៊ំ?

ខ៖ វាអត់ចាប់ទេគ្រាន់តែថាយើងគ្នាពទ្ធ័អីចឹងទៅយើង
អាខ្លះគេឆ្លងទឹកទៅកោះគរទៅមីអូន។កះចាំ!!

ខ៖ ឆ្លងទឹកទៅខាងហ្នឹងទៅទៅត្រើយកើតអញ្ចឹងទៅ ទៅត្រើយកើតព្រៃកតាជ័រព្រៃកអីអញ្ចឹងទៅ
គេចេះតែទៅអត់ហ៊ានយើងទៅក្រោមវិញទៅស្រែអីអញ្ចឹងទៅណាស់ទៅអីចឹង!!បានយើងឡើងហ្នំពួកអង្គការគេហ្នឹងគេថាហ្នំទៅនេះទៅណោះយើងចេះតែទៅទៅ
ញ៉ុមខ្សៀតរហូតទៅដល់កោះធំហ្នំ!!កំពង់ចាមក្រោមកោះធំហ្នំ!!ជាប់ផ្សារកោះធំម៉ង!!

កះចាំ!!

ខ៖ ពីរនាក់ប្ដីប្រពន្ធហ្នឹងទៅនៅកោះធំម៉ង។

កះ ពេលហ្នឹងអត់ទាន់មានកូនទេ?ខ៖ អត់!!កះ
ពេលហ្នឹងបើមានកូនអញ្ចឹងក៏ពិបាកដែរអំណោះ?

ខ៖ ក៏វេទនាដែរកូនអើយ!!

កះមិនដឹងរស់មិនដឹងស្លាប់ទេ!!

ខ៖ វាអត់មាននេះផង
យើងសំរាលកូននៅមន្ទីរពេទ្យហើយក៏អត់មានជិតដល់អីសួរអីនាំអីអត់បានទេ
ទាល់តែយើងចេញមកមានថ្នាំមានអីណាមានអាថ្នាំខ្មែរថ្នាំអីមកអញ្ចឹងទៅណាស់។

កះចាំ!!!

ខ៖
រឿងស្រាអីគេមិនអាចអោយយើងសរសៃខ្ចីបានស្រួលដូចយើងនៅសម័យឥឡូវណាស់!!ចង់ចាក់ថ្នាំអីបានឥឡូវកើត ជំនាន់អាពតអត់ទេ ខ្លះបានថាឆ្អើរបាន៣ថ្ងៃគេដាក់ចង្ក្រានហើយ។

កះហ៊ឹៗ!!

ខ៖ ហើយបាន៣ខែយើងត្រូវធ្វើការ។

កៈ៣ខែបានបានធ្វើការដែរ?

ខៈ ចាំ!!

កៈ ហ៊ីយូរដែរតើអំហោ??

ខៈ ៣ខែគេអោយយើងធ្វើការស្រាលៗអីអញ្ចឹង ត្រូវចិតចេកចិតអីអញ្ចឹងយើងមើលកូនទៅ។

កៈហ្ហ៎!!

ខៈ ធ្វើនេះធ្វើនោះយើងស្រាលៗ។

កៈចាំ!!

ខៈ ដល់ពេលកូនយើងធំត្រឹម៥ ខែ៦ខែយើងចុះស្ទូងហើយ។

កៈ អញ្ចឹងការងារគេហ្នឹងកាប់តែដីស្ទូងដាំបន្លែតែប៉ុណ្ណឹង!!!

ខៈ ដាំបន្លែផ្សេងទេ ខ្ញុំរឿងមួយជាតិជំនាន់ប៉ុល ពតមកខ្ញុំដឹងតែស្ទូងជាន់ទឹក រ៉ែកណ្ដុរយប់!!

កៈ ដាក់កណ្ដុរទៀត?

ខៈ រ៉ែកណ្ដុរ យើងធ្វើព្រួលរស់!!

កៈហ្ហ៎!!

ខៈ ព្រួលងាប់គឺជាព្រួលដែរគេក្រងឬស្សីដែលយើងបិតពទូសៗៗហាំ!!
គេដាក់របាំងមកហូតអ៊ីចឹងជុំវិញសងខាងយើងពីត្បូងមកព្រួលរស់ហើយណាស់យើងចេះតែ
ដេញស្រែករ៉ែកៗៗយកឈើមកកណ្ដុផ្អើលគេដាក់លប
គេដាក់លបប៉ុនៗនេះបីបួនខ្សែសងខាងទៅវាចូលណែនៗលបទៅណាអូន!!

កៈអូយច្រើន!!

ខៈ ហើយវាច្រើនហាហើយម៉ោង៧វាអត់មានភ្លើងអត់មានអីទេយើងគប់អាដេញចំបើងហាំ!!

កៈហ៊ីៗ!!

ខ៖
យើងដុតចេះតែបំភ្លឺទៅយើងទេសកាលអីអត់មានពោះអត់មានអីយារយើយើងដៃរអូនណាស់។

ក៖ចាំ!!

ខ៖ យើងធ្វើតែល្អ!!

ក៖ចុះកណ្តុរហ្នឹងដល់ពេលបានមកគេយកទៅហូបឬក៏គេយកទៅវ៉ៃចោលអ៎ំ?

ខ៖ គេវ៉ៃចោលគេមានអោយយើងហូបអីណា!!

ក ៖តែដល់ពេលដូចកណ្តុរស្រែអញ្ចឹងគេហូបបានតើអ៎ំហោ?

ខ៖ គេហូប ប៉ុន្តែគេអត់អោយហូប។

ក៖ គេយកទុកខ្លួនគេហី?

ខ៖ អត់ ។

ក៖ វ៉ៃចោលងាប់?

ខ៖ វ៉ៃចោលងាប់ទៅ!!!គេអត់អោយយើងហូបទេ។

ក៖ខ្លាចឆ្អែត!!

ខ៖ គេអត់អោយយើងហូបម៉ង!!

ក៖ ហើយអ៊ីចឹងអ៎ំដល់ពេលវ៉ៃកណ្តុរវ៉ៃអីយប់អញ្ចឹងមានបានបូតស្រូវបូតអីហូបខ្លះទេអ៎ំ?

ខ៖អត់ទេអ៎ំអត់ដែលមានប៉ះពាល់អីម៉ង!!អត់ទេ!!បើថាខាងបាត់ដំបងលឺគេនិយាយថាបូតក៏ស្រូវបូតអី អ៎ំអត់ទេ កន្លែងទីធ្លាហ្នឹងសុទ្ធតែជំឡូងឈើនេះអ៎ំអ្នកដាំអ្នកធ្វើហើយនេះ។

ក៖ហ៊ឺៗ!!

ខ៖ចង់ដកអោយដូចថាឃ្លាន
សហាករណ៍គេតំរូវប៉ុន្មានអ៊ីចឹងទៅគេដកទៅគេយកធ្វើអីធ្វើទៅគេយកធ្វើនំប៉័ងនំពួយអីគេធ្វើ

ទៅហើយពីហ្នឹងទៅសំរុកស្ទូង
ស្ទូងហើយច្រូតកាត់ហើយហ្នំទៅវ៉ៃភ្លឺហិចតាទៅវ៉ៃម៉្ភុំសិត្បទៅទៅវ៉ៃអញ្ចឹងល្ងាចមកផ្ទះវិញមក។

កះហ៊ឺ!!ធ្វើតែការងារអញ្ចឹងៗទៅអ៊ំ?

ខះ ធ្វើរហូតហ្នឹង ថាមួយជីវិតនេះគឺ!!

កះតែស្រែចំការដាំដុះអីអញ្ចឹងទៅ!!

ខះ តែស្រែចំការ។

កះ ដាំដុះអីអញ្ចឹងទៅអ៊ំណោះ?

ខះអត់បានស្រួលនឹងគេទេ!!ពិបាកទាំងកាយពីបាកទាំងចិត្ត។

កះ តែពេលហ្នឹងគេមានធ្វើបាបធ្វើអីអ៊ំទេ?

ខះ អត់មានដែលអត់!!

កះ ស្រួលដែរហ្នឹងអ៊ីចឹង!!

ខះ គ្រាន់តែថាហូបដឹងរបបគេអញ្ចឹង
ឥឡូវមកព្រលឹមឡើងអញ្ចឹងគេអោយមករបបពោតក្រហាមមួយប៉ុណ្ណឹងអ៊ិចឹងណាស់យើងហូប
ទៅពេលថ្ងៃត្រង់ជួនកាលពោត៣ហូបទៅ ហូបជាមួយសំលរម្ជូរចេក សំលរម្ជូរដើមចេក
សំលរជាមួយត្រកួនអីអញ្ចឹងទៅណាស់ យើងចេះតែហូបទៅ។

កះ ហូបពោតជាមួយទឹកសំលរ?

ខះ ចាំ!!ពោតស្ងោរហាំ!!

កះចំលែកណាស់អ៊ំ!!

ខះ ចាំហូបជាមួយពោតស្ងោរអ៊ីចឹងទៅ ជួនកាលគេថាហ្វំរបបអត់មានអង្ករទេ
ចេក៥ប៉ុនៗមេជើងមីអ្វូនឯងចេក៥ហ្នឹងហូបជាមួយទឹកសំលរហ្នឹងទៅ។

កះហ៊ឺៗ!!

ខៈ ញ៉ុមអត់ហូបជាមួយទឹកសំលរហ្នឹងទេញ៉ុមហូបទទេជាមួយអំបិលហ្នឹង ចប់ទៅព្រលឹមឡើងគេអោយពោតមួយវិញហើយ របបពោតមួយ!!!

កៈចាំ!!!

ខៈ ថ្ងៃត្រង់ពោត៣។

កៈហើយអត់បានបបរបាយហូបទេអ៊ំហី?

ខៈ បបរដល់ពេលអជ្ឈុស កក្តិក។

កៈ អញ្ចឹងមានតាមខែគេ?

ខៈ អជ្ឈុស កក្តិកដូចថាដាច់ស្បៀងអ៊ីចឹងយើងទៅបោចកំផ្លោកទឹកត្រឹមៗនេះអីហ្នឹង។

កៈហ៊ឺៗ!!

ខៈញ៉ុមទៅបោចទៅថ្ងៃត្រង់គេយកបបរអោយហូប តែយើងហូបបបរយើងអូសអ៊ីចឹងទៅហើមមុខតើ!!ត្រជាក់ហាំ!!

កៈហ៊ឺៗ!!

ខៈ ហើមមុខហើមអីអញ្ចឹងទៅហើយញ៉ុមអត់ដែលឈឺទេ។

កៈហេងហើយអញ្ចឹង!!អត់ដែលសូវឈឺទេ រៀងឈឺក្បាលឈឺអីបន្តិចបន្តួចហ្នឹងទៅគេអោយថ្នាំហ្នឹង ថ្នាំខ្មៅៗហ្នឹងចេះតែលេបទៅ។

កៈ គេហៅថ្នាំអាចមន៍ទន្សាយហ្នឹងអី?

ខៈអើរចេះតែលេបទៅមីអូន ចេះតែជាដែរអត់អីដែរ។

កៈ ហេងហើយអ៊ំណោះ?

ខៈ ចេះតែជាទៅ ធ្វើតែប៉ុណ្ណឹងអត់មានធ្វើអីទេញ៉ុម។

កៈ ចុះអ៊ំញ៉ុមលឺនិយាយថានេះញ៉ុមសំភាសន៍អ្នកនៅកោះគរអីវ៉ាន់នេះអ៊ំហ៊ា
លឺល្បីថានៅកោះគរហ្នឹងគេសម្លាប់មនុស្សសាហាវណាស់អ៊ំហេ?

ខៈ
គេសម្លាប់តើមីអូនពេលញ៉ុមនៅផ្ទះមាត់ព្រែកខាងណោះពេលនៅផ្ទះជាប់ថ្មល់ខាងលិចហ៎ា!!

កៈហ៊ីៗ!!

ខៈ ពេលល្ងាចត្រជាក់ជាងនេះបន្តិច គេបញ្ចេញពួកកោះគរមកបង្រៀបដីហ៎ាកូន!!
នង្គល័ហ្នឹងព្យួរមនុស្ស។

កៈចា៎!!

ខៈ
ហើយគេអ្នកធ្វើការស្រីប៉ុណ្ណឹងទៅយើងម្នាក់ប៉ុនគេមួយដូចថាដីខ្ពស់យើងកាប់ពីដីខ្ពស់យកមក
បោះទាបខ្ពស់មកបោះទាបខ្ពស់មកបោះទាបអញ្ចឹងទៅណាស់
បង្រៀបវាហើយអីហើយថាដល់ម៉ោងហើយគេអោយមុជទឹកតាមជួរហ៎ាអ្នកក្បាលទីគឺបានដុះ
ខ្លួនអ្នកចុងទីគ្រាន់តែជ្រលក់ឡើងទេណាស់។

កៈ គឺចេះតែអញ្ចឹងម៉ង!!

ខៈញ៉ុមសំណាងហើយអត់មានកូនជំនាន់អាពតញ៉ុមសំណាង។

កៈ ចា៎ហេងហើយអ៊ំដែលពេលបែកហើយបានមាន!!

ខៈសំណាងបែកហើយបានមាន។

កៈចុះបងណាងពេលបែកមកបានមានគាត់មែនឬក៏នៅក្នុងហ្នឹង?

ខៈ ចា៎បែកប៉ុលពតហើយបានមាន!!

កៈហ្អ៎!!

ខៈញ៉ុមសុំកូនធម៌នោះនៅផ្ទះត្បូងកូន៩។

កះចាំកូនធមិរបស់អ៊ំហ្នឹងហី?

ខះ ចាំ!!

កះ នៅជាមួយអ៊ំរហូត?

ខះនៅតាំងពីអាយុ១២ឆ្នាំ។

កះហើយចុះឪពុកម្តាយរបស់គាត់ទៅណាវិញ?

ខះ
ដល់ពេលបែកហើយយោញ៉ុមថាមីអូនហាំទៅឪហី?វាថាអត់ទៅទេម៉ែព្រោះអីញ៉ុមនៅស្ពានជ្រោយចង្វាតាំងពីទូចដែរនៅជាមួយម្តាយហាំ!!

កះចាំ!!

ខះដូចថាម្តាយកូនច្រើនណាស់យកទៅអោយទៅមើលកូនគេណាកូន
កូនគេអីចឹងវាបានលុយជួយចិញ្ចឹមប្អូនទៅណាស់ គ្នាក៏កំសត់ដែរ។

កះចាំ!!

ខះ បានប្តីក៏ដោយធមិដែរ!!

កះហ្អ៊ំ!!

ខះ វាអត់អោយធ្វើអីអោយតែមានកូននៅផ្ទះរហូតស្រណុកជាងញ៉ុមផង។

កះ តែអត់ទៅរកម្តាយឪពុកវិញទេ?

ខះ ខ្ញុំសួរដែរថាហ្អែងនៅណា វាថាវាអត់ស្គាល់វាអត់ចាំអត់អីខ្ជិលណាស់!!

កះ អញ្ចឹងក៏ចប់ត្រឹមហ្នឹងទៅ!!

ខះអញ្ចឹងក៏អត់ទៅរក ក៏ចប់ត្រឹមហ្នឹង
ញ៉ុមថាលោអោយថាអស់ឪពុកមីងមាក៏នៅមានម្តាយធំដែរណាស់អោយដឹងថាកូនមីនេះរស់អីចឹងហាំ!!

កៈចាំ!!អញ្ចឹងអ៊ំសំរាប់អ៊ំមិញអត់ទាន់និយាយអាកន្លែងកោះគរមិញផងហ្នឹងម៉េចដែរសម្លាប់មនុស្សហាំ?

ខៈ សម្លាប់មនុស្សតើមីអូន។

កៈ ម៉េចវិញ?

ខៈ យប់ឡើងលឺស្រែកជួយផងម៉ែ យើងអត់បានឃើញផ្ទាល់នឹងភ្នែកទេណាស់!!!

កៈតែលឺសំលេង?

ខៈ
លឺសំលេងស្រែកពេលយប់ម៉ោង១២យប់ម៉ោង១អីអញ្ចឹងទៅណាស់ញ៉ុមដេកអត់លក់អញ្ចឹងទៅណាស់ចេះតែភ័យហាំ!!

កៈហ៊ឺៗ!!

ខៈជំនាន់ប៉ុល ពតហ្នឹងប្តីញ៉ុមហ្នឹងក៏ចូលកងចល័តដែរ។

កៈចាំ!!

ខៈកងចល័តយើងនៅនេះនៅលូនេះ លូទីមួយនេះ!!

កៈ ចាំចាំ!!ស្គាល់ហើយ។

ខៈ ប្រវែងហ្នឹងផ្ទះហ្នឹងគេអត់អោយនៅដេកផ្ទះទេណាស់!!

កៈ តែមកបាញ់ម៉ងអ៊ំហោ?

ខៈ
ហ្នឹងហើយស្រាប់តែមកអញ្ចឹង៧ថ្ងៃគេអោយមកម្តង!!ទៅមុនធាត់ហាំដល់តែពេលយូរៗដូចក្មេងបាក់ទឹកដោះអញ្ចឹងគេធ្វើបាបរហូតអីចឹងទៅណាស់
ដូចថាអោយធ្វើហួសកំរិតអោយយើងហូបរបរបីស្លាបព្រា
អូនឯងហូបឆ្អែតដែរមនុស្សប្រុស!!បីស្លាបព្រាអ៊ុយ អេសហាំ!!

កះ តែញ៉ុមមួយគោមមិនឆ្អែតផង។

ខះ យើងទ្រាំមិនបានយើងគេយកទៅកោះគរ
យើងទ្រាំបាននៅរស់អញ្ចឹងទៅណាស់។កះចាំ!!ខះហើយគាត់ចេះតែទ្រាំទៅមកផ្ទះយើងអញ្ចឹង
យើង៣វែកអញ្ចឹងអត់ហ៊ានហូបអស់ទេអូនអើយហូបតែមួយវែកៗទុកពីរវែកអោយគាត់មកផ្ទះ
ដូចថាដឹងគាត់មកអញ្ចឹងណាស់!!ទុកទៅសុំអំបិលគេបន្តិចទៅអោយគាត់ហូបទៅឆ្អែតហ្នឹងអា
ហ្នឹងបានឆ្អែត ។

កះ អត់មានជំនាំជំនោចអីបេះហូបបានទេអ៊ំ?

ខះ អាណាគេអោយបេះ គោស៊ីស្លឹកស្វាយខ្ទាំងហើយ
អូនឯងម៉េចធ្វើអញ្ចឹងអាណាទៅបេះរបស់គេ
នេះម្ដុំហ្នឹងចេកទុំពេញដើមហ៊ិ!!មានអាណាហ៊ានកាប់ទេអូន
អត់ហ៊ានសោះតែស្អីក៏ខ្ញុំក៏មានហ៊ានដែរតែរបបគេចែកមកប៉ុន្មានញ៉ុមហូបប៉ុណ្ណឹងហើយ
ញ៉ុមអត់ហូបច្រើន។

កះ ហើយអ៊ីចឹងម៉េចបានទ្រទ្រង់ខ្លួនប្រាណបានកើតអ៊ំ?

ខះ ញ៉ុមមិនមែនស្គមអញ្ចេះទេ
ញ៉ុមធាត់ណាស់ដើរពីហ្នឹងទៅត្រឹមវត្តអីដើរពីរបកឥឡូវលោកក្រលៀនឥឡូវហ្នឹង។

កះហើយពេលនៅជំនាន់ប៉ុល ពតធាត់វិញ?

ខះ ធាត់ហើយហូបបាយប៉ុននេះៗទេ។

កះទៅអញ្ចឹងវិញ?

ខះ ហ្នឹងហើយ។

កះ ហ៊ុចំលែកណាស់អ៊ំ!!

ខះ ដូចថាយើងអត់សូវពិបាកចិត្តដូចឥឡូវណាស់មីអូនណាស់។

កះហ្ហ៎!!

ខ៖ ណាមួយកូនដើរយើងគិតខ្លាចមានគ្រោះថ្នាក់លោរអីម៉េចម៉ាដើរខុសគន្លង ច្បាប់ឥឡូវគេចាប់ដាក់គុកមិនអញ្ចឹងហោ?

ក៖ចាំ!!

ខ៖ យើងម៉ែហ្នឹងចេះតែបារម្ភដេកមិនលក់បក់មិនល្ហើយ ជំនាន់អាពតស៊ីហើយដេកហ្នឹងគិតរឿងអី?

ក៖ ដឹងតែព្រលឹមឡើងធ្វើការទៀត!!

ខ៖ ដឹងតែព្រលឹមឡើងធ្វើការយើងមានលុយកាក់ណា!!ដឹងថាគេអោយស៊ីអញ្ចឹងដឹងតែមានកំលាំងធ្វើ។

ក៖ ពេលហ្នឹងបើសិនជាអ៊ំបើសិនជាអញ្ចេកបើសិនជាអោយហូបឆ្អែតទៀតហាំអត់អីទេអ៊ំហោ?

ខ៖ អត់អីទេ!!

ក៖តែរឿងយ៉ាប់គឺរឿងសម្លាប់ហើយនឹងអត់អោយហូបហ្នឹងតែម្តង!!

ខ៖ ហ្នឹងអត់អោយហូប ពួកនារីៗអីវ៉ាន់ញ៉មទៅឃើញពួកទៅធ្វើអីនៅហ្នឹងចេះតែអោយបាយអោយអីចេះតែនឹកឃើញកូនគេកូនយើងអូន!!

ក៖ អញ្ចឹងអ៊ំអ្នកកាន់ចង្ក្រានបាយឬក៏អី?

ខ៖ អត់ទេអ៊ំទៅធ្វើគេចងក្រុម ដូចថា១០នាក់អីចឹងអ៊ំមើលការខុសត្រូវអីអញ្ចឹងទៅណាស់!!

ក៖ហ៊ីៗ!!

ខ៖ឥឡូវថា១០នាក់ទៅធ្វើនៅហ្នឹងអ៊ំថាណៃពួកសេដ្ឋកិច្ចហាកន្លែងញ៉ុម១២អញ្ចឹងលើស២នាក់អញ្ចឹងទៅណាស់!!វាបាយអោយកូនថៅស៊ីឆ្អែតផង។

ក៖ហ៊ីៗ!!

ខ៖គ្នាចម្អតាឆ្អែតបានមានកំលាំង។

ក៖ចាំ!!

ខ៖ យើងយល់គេអីចឹងដែរ តែភរគេរហូតហ្នឹង។

ក៖ហ៊ឹៗ!!

ខ៖បានបាយច្រើនអោយកូនចៅស៊ីអោយកូនចៅហូបហើយសល់ក្មេងៗមកអញ្ចឹង ដូចអំសុំបាយហូប
យើងអោយបាយហូបនៅហ្នឹងទៅទៅរកហូបណាគេឃើញគេវ៉ៃចោលហាំ!!ក្មេងៗនៅហ្នឹងហាំ អូនឯងហូបអោយឆ្អែតហើយហើយរូតទៅវិញ!!ចេះតែអានិតហាំ!!

ក៖ ចាំមែនហ្នឹងអ៊ំជីវិតហាំ!!ជីវិតគេជីវិតយើងអី!!

ខ៖ ចេះមានមេត្តាទៅណាស់!!

ក៖ចាំ!!

ខ៖ ហើយញ៉ុមបើសិនជាម៉ែញ៉ុមចង់អីអញ្ចឹងណាស់
ញ៉ុមធ្វើការសហករណ៍គេហ្នឹងម៉ោងដូចថាហូបបាយម៉ោង១១
ម៉ោង១១ហើយយើងធ្វើអីធ្វើទៅយើងអត់មានគិតគូរអីទេ យើង១យើចូលធ្វើហាំ
ញ៉ុមទៅរាវក្តាមរាវអីបានដាក់ទុកក្នុងស្នុកអីទុកអោយម៉ែ។

ក៖ហ៊ឹៗ!!

ខ៖ គេអោយបោចកំផ្លោកពស់ព្រលិតអីញ៉ុមវៃទៅយកអោយម៉ែញ៉ុមវ៉ៃយកមកអោយម៉ែញ៉ុម តែឥឡូវគ្រើរស់ញ៉ុមអត់ហ៊ានវ៉ៃផង។

ក៖
ហ្នឹងហើយអ៊ំអើយ!!សូម្បីមិនចាំបាច់តែថាអ៊ំទេសូម្បីតែញ៉ុមឥឡូវហ្នឹងអោយកាប់អោយធ្វើគ្រើរស់អីហ្នឹងញ៉ុមខ្លាចណាស់ ទាល់តែងាប់បានញ៉ុមធ្វើកើត!!

ខ៖ ឥឡូវប្រាថ្នាជាតិណាៗអោយជួបតែល្អអញ្ចឹងទៅណាស់។

ក៖ចាំ!!

ខ៖កុំអោយពិបាកចិត្តអ៊ីចឹងទៀត ហើយតំរិះហ្នឹងក៏អោយបានខ្ពង់ខ្ពស់ជាងហ្នឹង។

ក៖ចាំ!!បានអាភាមួយគេធ្វើការអរ។

ខ៖ចាំអ៊ីចឹងអ៊ំសំរាប់ជីវិតរបស់អ៊ំ អ៊ំជួបការងារអីគេខ្លះនៅក្នុងជីវិតហ្នឹង
អ៊ំរៀបរាប់តាំងពីដំបូងរហូតដល់ឥឡូវមើលអ៊ំធ្វើការអីគេខ្លះ?

ខ៖ អ៊ំធ្វើការធ្វើតែចំការហ្នឹង។

ក៖តែមួយហ្នឹងទេហោ?

ខ៖ តែមួយហ្នឹង ដកស្ទូង លើកភ្លឺ ច្រូតស្រូវជាន់ទឹកតែប៉ុណ្ណឹង!!

ក៖ ចុះពេលបែកប៉ុល ពតមកគេមិនខ្វះគ្រូ អ៊ំមិនព្រមចូលធ្វើគ្រូធ្វើអីទៅ?

ខ៖ ថាវាសយខ្ញុំទេញ៉ុមគិតថារកចូលធ្វើគ្រូនឹងគេហើយ
ប៉ាវាថាឯងចូលធ្វើបានអាណាដាំបាយអោយកូនស៊ីហ្នឹង?

ក៖ ចុះធ្វើមិនមែនទាំងព្រឹកទាំងល្ងាចណាហី?

ខ៖ គេរៀនតែមួយព្រឹកៗហ្នឹង ចុះគាត់មានមុខរបររកដាក់ទឹកផង
ដាក់ទឹកតាមផ្ទះអ៊ីចឹងណាស់អូន។

ក៖ចាំ!!

ខ៖ទឹកផងអីអញ្ចឹង
ព្រលឹមឡើងយើងលក់កាហ្វេនាយអាយអញ្ចឹងទៅខ្លះៗចិញ្ចឹមកូនអ៊ីចឹងទៅណាស់
តេកតក់ៗហ្នឹង កាលមុនកាហ្វេខ្មៅមួយកែវ៣០០ហ្នឹងហោ
កាហ្វេទឹកដោះគោមួយកែវ៥០០ហ្នឹងហើយបានស្អី!!

ក៖ ឥលូវមិនបាច់លូក!!

ខ៖ មិនបាច់លូក!!

កៈ ២០០០ ៣០០០។

កៈ ២០០០ កាហ្វេទឹកដោះគោ២០០០ហើយ។

កៈចាំ!!

ខៈ
ហើយញ៉ុមលក់ពេលយប់ទៅទឹកស៊ីរ៉ូអីញ៉ុមចេះតែលក់ទៅគ្រាន់តែកូនបានចេះធូរធារតិចទៅណាស់!! កូននេះណាស់មីធំធ្វើការ ធំឡើងញ៉ុមមិនដែលយកលុយមួយរៀលទេធ្វើការដល់ចាស់ ធ្វើអីធ្វើទៅស្រេចតែវា ដល់ពេលពួកញ៉ុម២នាក់បានលើញ៉ុម
បានលក់ដីបាននៅតាដោរបានធ្វើផ្ទះនេះបានទៅហើយលក់ដីនោះទៅញ៉ុមមានអីញ៉ុមអត់មានអីទេជីវិតដូចថាពិបាករហូតអត់មានស្រណុកស្រួលកាយស្រួលចិត្តអីទេ!!
តែនឹកឃើញថាតស៊ូក្នុងជីវិតនេះពិបាកម៉េចក៏ខំតស៊ូទ្រាំប៉ុណ្ណឹងដូចថាប្រាថ្នាជាតិក្រោយទៅញ៉ុមសុំស្រួលជាងហ្នឹងតិចទៀតទៅណាស់!!

កៈចាំ!!

ខៈមិនដឹងទៅម៉េចទៅម៉ាយើងសុំតែស្រួលអញ្ចឹងម៉ង!!

កៈ ជីវិតឥលូវ!!តែជីវិតឥឡូវគ្រាន់បើហើយអំណោះសង្ឃឹមលើកូនហើយអំណោះ?

ខៈ កូនឥឡូវអត់មានការងារធ្វើផងកូនឥឡូវអូនអើយ!!

កៈ ចុះឥឡូវមានដីចំការមានអីធ្វើទេអ៊ំ?

ខៈអត់!!!

កៈ អស់រលីងហើយ?

ខៈ ញ៉ុមថាធ្វើបានធ្វើសំរាប់តែគាត់លក់ជំងឺរបស់គាត់តាំងពីមីអស់ហ្នឹងជំទើរជំទើរនោះឥឡូវអស់ហើយមិនសល់អីទេ!!

កៈចាំ!

ខៈម៉ែនៅនេះគ្រាន់តែសល់ដីតិចៗគ្រាន់ចែកកូននៅទៅ!!

កៈ បានមួយជ្រុងៗម្នាក់អញ្ចឹងទៅ!!

ខៈចាំ!!!

កៈ ដីទៅក្រោយទៅក្រោយវែងតើអ៊ំហី?

ខៈ អត់ទេលក់អស់ហើយនៅសល់ប្រហែល២ឡូហ្នឹង!!មីនេះមួយឡូ អាពៅមួយឡូ។

កៈចាំ!!

ខៈគ្រាន់តែថាជីវិតខ្ញុំវាកំសត់ណាស់គ្មានអីវាអាងធំធាត់នឹងគេទេអត់ទេ ស្អាតម៉ង!!

កៈអ៊ីចឹងអ៊ំឥឡូវនៅតែផ្ទះមើលតែចៅអញ្ចឹងទៅអ៊ំណោះ?

ខៈ អើរពេលកូនអត់ធ្វើការយើងទៅស៊ីឈ្នួលដកស្មៅខ្ទឹមគេទៅណាស់!!

កៈហ្ហ៎អ៊ីចឹងមានគេដាំខ្ទឹមនៅក្រោយៗអ៊ំហេ?

ខៈ ចាំ!!ដាំខ្ទឹម ដាំអំពៅ សិកអំពៅ ធ្វើជើងអំពៅយើងចេះតែធ្វើទៅពោតអីវ៉ាន់ចេះតែធ្វើ ។

កៈ ឥឡូវពោតអីវ៉ាន់នៅក្រោយសំបូរអ៊ំហេ?

ខៈ ទៅត្រើយណោះគេអត់ទាន់លក់ដីគេដាំតើកូន។

កៈចាំ!!

ខៈ ដាំពោតអ៊ីចឹតងទៅដល់ធំទៅគេដាក់ជីដូចអ៊ំថាអញ្ចឹងហិ
ត្រឹមកំពស់នេះគេរោយថ្នាំបណ្តូលពោតហាំ!!

កៈហ្ហ៎!!

ខៈហើយអញ្ចឹងបានគេលុបគល់លុបហើយអីហើយគេដាក់ទឹកអញ្ចឹងបានគេបាញ់ថ្នាំទៀត។

កៈ អ៊ីចឹងអ៊ំទៅស៊ីឈ្នួលធ្វើជើង?

ខៈ ទៅស៊ីឈ្នួលគេហ្នឹង ធ្វើអញ្ចឹងទៅ កូនថ្ងៃណាគេទំនេរ!!អញទៅរកលុយចាយទៅទៅ
ពេលណានេះគេធ្វើទៅការយើងមើលកូនដឹកកូនគេទៅរៀន ។

កៈចាំ!!

ខៈហើយដាំបាយអោយវាស៊ីហ្នឹង!!

កៈ
អញ្ចឹងអ៊ំមួយនេះគឺជាសំនួរមួយចុងក្រោយតើអ៊ំមានពាក្យពេចន៍អីគេខ្លះដែរចង់ណែនាំក៏ដូចជាទូន្មានទៅកាន់កូនចៅជំនានន់ក្រោយហាំថាអោយគាត់ដើរលើផ្លូវម៉េចដែរហើយថាចង់ផ្ដែផ្ដាំអីតាមចិត្តអ៊ំឬក៏ចង់និយាយអីបន្ថែមអញ្ចឹងទៅណាស់?

ខៈ មានផ្ដាំអីនេះ
ផ្ដាំថាអោយកូនអោយធ្វើតែល្អទៅព្រោះសង្គមឥឡូវគេចង់អ្នកចេះច្រើនអញ្ចឹងណាស់កូន។

កៈចាំ!!

ខៈ ចេះដឹងច្រើនបានការងារក៏ល្អ
ហើយអ្នកល្ងិតល្ងង់គឺមានតែសំនង់ហើយគឺធ្វើសំនង់ហើយព្រោះញ៉ុមរាល់ថ្ងៃហ្នឹងថាកូនហ្នឹងធំៗទៅធ្វើការរៀនបានសូត្រធំៗបានធ្វើការធំៗវាស្រួលចិត្តដូចខ្ញុំវាហួសហើយវាឈប់និយាយហើយ តែប៉ុណ្ណឹងទេ!!

កៈ អញ្ចឹងមានតែធម៌អារ្យហើយមែនទេអ៊ំណោះ?

ខៈ មានតែធម៌អារ្យទៅមុខហើយ។

កៈ
ចាំហ្នឹងហើយអញ្ចឹងអរគុណច្រើនអ៊ំសំរាប់ការសំភាសន៍ដ៏ក្បោះក្បាយដែលអ៊ំបានរៀបរាប់ប្រាប់អ៊ីចឹងណាស់
អ៊ីចឹងគឺការសំភាសន៍មួយនេះគឺរក្សាសំរាប់កូនចៅរបស់អ៊ំជំនាន់ក្រោយអោយគាត់បានស្ដាប់ហើយឬក៏កូនខ្មែរជំនាន់ក្រោយហើយឬក៏ជនជាតិណាក៏ដោយគេចង់សិក្សារឺស្វ័យយល់ពីរប្រវត្តិប្រជាជនខ្មែរយើងថាការរស់នៅក៏ប្រវត្តិពីមុនមក!!

ខៈ ប្រវត្តិពីដើមមក!!

កៈចាំ!!ជួបរឿងអីគេខ្លះ។

ខ៖ចាំ!!

ក៖
នៅក្នុងប្រវត្តិសង្គ្រាមអីវ៉ាន់ហ្នឹងណាស់!!អីចឹងគេនឹងចូលទុកនៅក្នុងកន្លែងអារក្សាសំលេងមួយហ្នឹងអញ្ចឹងទៅណាស់!!

ខ៖ចាំ!!

ក៖ អញ្ចឹងមានវ៉ែជាភាសាខ្មែរក៏ដូចចេញបកប្រែជាភាសាអង់គ្លេស!!

ខ៖ អង់គ្លេស!!

ក៖ ដើម្បីអោយពិភពលោលស្គាល់អញ្ចឹងទៅអ៊ំ!!

ខ៖ចាំ!!

ក៖អញ្ចឹងពួកគាត់អាចសិក្សាស្វែងយល់ពីប្រវត្តិរបស់ប្រជាជនកម្ពុជារបស់យើង។

ខ៖ចាំ!!តែគេមិនធ្លាប់ពីបាកដូចញ៉ុមគេអត់ដឹងទេ!!

ក៖ចាំហ្នឹងហើយដោយសារពេលខ្លះនៅប្រទេសខ្លះគេស្រួលរហូត។

ខ៖ស្រួលរហូត!!

ក៖ គេទំនើបអីៗទំនើបទាំងអស់!!

ខ៖ហ្នឹងហើយ។

ក៖អត់បានភ្លក់រសជាតិអីវ៉ាន់វេទនាលំបាកដូចជាប្រទេសយើងអញ្ចឹងទេអ៊ំ!!!

ខ៖ចាំ!!

ក៖ប្រទេសគេគេកើតមកគេសន្តិភាពគេអត់មានសង្គ្រាម។

ខ៖សន្តិភាពអត់មានសង្គ្រាម យើងពីរដងបីដងណោះ!!

ក៖ហើយវិញម្តងៗចង់រលាយរលត់អស់រលីងហើយ!!

ខៈ យើងចង់រលាយរលត់អស់ហើយហ្នឹង!!!

កៈហ្នឹង!!!ចាំ!!

ខៈ មើលគុកទួលស្លែងមើលយកទៅណាស់អស់!!

កៈចាំ!!

ខៈញុំមអត់ដែលឃើញគេដកក្រចកទេណាស់កូន!!

កៈចាំ!!

ខៈខ្ញុំបែកហើយណាស់
បែកហើយញុំមទៅរស់នៅលើវត្តព្រែកសំរោងហ្នឹងខ្ញុំពោះធំមីហ្នឹង៣ខែគេយកញុំមដាក់អើរវត្តទួលទំពូងហាំ!!ស្គាល់ទេ?

កៈស្គាល់!!

ខៈ ដាក់ហ្នឹងដាក់ជាប់ហ្នឹងរយៈចូល២ខែដែរទាំងប្តីទាំងប្រពន្ធ
ដាក់ខុសគ្នាប្រុសដេកប្រុសស្រីដេកស្រី។

កៈចាំ!!

ខៈនៅលើសាលារៀនគេហ្នឹងអាពជាន់ហ្នឹងពីរជាន់ហ្នឹង។

កៈចាំ!!

ខៈនៅលើគេ អើរបីបួនថ្ងៃបានញុំមបានបានមុជទឹក។

កៈនៅលើហ្នឹងរហូតម៉ង?

ខៈ
ចាំ!!ដល់ពេលពួកយួនយួនវានៅកាន់កាប់អ្នកទោសហ្នឹងហាំហើយមានគេចេះបកប្រែអញ្ចឹងទៅគេបកប្រែចេះៗទៅខ្ញុំក៏កាលហ្នឹងពាក់ក្រវិលផ្កាក្រសាំងមាសហាំ!!វាចង់បានអញ្ចឹងទៅវាដូរអញ្ចឹងទៅវាដូរពោតបង្កងវាមិនមែនយកទទេទេណាស់មួយជីហ្នឹងវាដូរពោតបង្កងពីរវង់។

កៈ ពោតបង្កងម៉េចអ៊ំ?

ខៈ ក្រវិលពោតបង្កងយើងស៊ិកហ្នឹង។

កៈហ្ហ៎ៗៗស្គាល់ហើយ។

ខៈ ពីរវង់ហើយអាមួយវង់នោះ៥ហ៊ុនហើយអាមួយវង់នោះបានតែ៣ហ៊ុនទេ
ព្រោះអានោះវាស៊ិកសំណរចូលណាស់ យើងត្រូវបាត់ពីរហ៊ុនណាស់!!

កៈចា៎!!

ខៈឯងថាសួរប្តីថាគាត់ចង់បានអាហ្នឹងប៉ាឯងអោយអត់?អោយទៅ
អោយទៅបានស្អែកឡើងគេហៅញ៉ុមលាងចានអ្នកទោស មកអញ្ចឹងម្នាក់ៗធ្វើរក្រមាគក់
ក្រមាជ្រលក់ទឹកហា៎!!!ជ្រលក់ទឹកពូតអ៊ីចឹងជ្រលក់ចែកគ្នាជូត!!ទៅ
ក្រមាដូចថាមីអូនឯងធ្វើរអ៊ំអ៊ីចឹងហិមួយទៀតធ្វើរមកបានជូតទៅ
ខ្លះបីខែអត់ទាន់បានងូតទឹកទេ!!

កៈហ្ហ៎!!ហើយហូបអីហូបអីម៉េចទៅអ៊ំ?

ខៈ ហូបបាយអង្ករយើង អង្ករយើងមួយគ្រាប់!!!លាយពោតសាលីហា៎!!

កៈចា៎!!

ខៈអូនឯងដែលហូបទេ?

កៈ ស្គាល់ៗ។

ខៈ ហូបបើថាគេស្ងោរ ស្ងោរស្តែជ្រក់យើង!!ស្តែក្តោបហ្នឹងហា៎ !!

កៈចា៎!!

ខៈជ្រក់ហើយគេដាក់ឡាំងមួយយើងនោម
ឡាំងមួយជុះអាចមន៍គ្នា៣នាក់អញ្ចឹងទៅណាស់!!កៈហ៊ឺៗ!!

ខ៖ហើយយើងជុះហើយ ដល់ពេលវេន
វេនខ្ញុំយកទៅចាក់ចោលនៅក្នុងបង្គន់ហ្នឹងហា៎!!ថាក្អួតអើយក្អួតហើយពួកយួនហ្នឹងថាថី
ហើយអ្នកបកប្រែហ្នឹងថាថី ញ៉ុមថាញ៉ុមចាញ់កួន
ចង់ហូបផ្លែអំពិលទឹកនៅក្បែរការិយាល័យយើងពីដើមមានដើមអំពិលទឹកអញ្ចឹងណាស់!!ហើ
យថាញ៉ុមចង់ហូបផ្លែអំពិលទឹកហ្នឹង
ហើយដល់នេះញ៉ុមថាសុំទៅបេះបានទេ?អញ្ចឹងទៅយើងសួរវាហា៎
បើអញ្ចឹងទៅយើងអនុញ្ញាតទៅចេញពីហ្នឹង
ចុះទៅបេះបានហា!!វាថាចេញទៅបេះបានចេះទៅបេះទៅ!!យើងបានហូបទៅ!!

ក៖ចា៎!!

ខ៖បើពួកវាអត់អោយចេញយើអត់ទេ!!

ក៖តែពួកវៀតណាមចូលហើយហោ?

ខ៖ ពួកវៀតណាមចូលគ្រប់គ្រងមួយប្រទេសហ្នឹង!!

ក៖ហ្ហ៎!!ហើយចុះវានៅហាមឃាត់ធ្វើអីទៀតមិនព្រមអោយមកភូមិស្រុកអោយអស់វិញមក?

ខ៖ នៅទេ កាលហ្នឹងគេនៅសង្ស័យយើងប៉ុល
ពតដូចថាយើងធ្វើដូចថាគណៈក្រុមគណៈអីអីចឹងណាស់ !!

ក៖ហ្ហ៎!!

ខ៖ យើងមើលក្រុមៗអញ្ចឹងណាស់!!

ក៖ចា៎!!អញ្ចឹងមានអ្នកខ្លះបានធ្វើទ័ពប៉ុល ពតអីខ្លះដែរអត់ហោ?

ខ៖ ចា៎គេធ្វើធំៗអញ្ចឹងទៅគេ ខ្លះគេគេចរួចអាខ្លះគេនៅអញ្ចឹងទៅណាស់!!

ក៖ហ្ហ៎!!

ខ៖ហើយយើងធម្មតាកូនក្រុមយើងទៅខ្វល់អីគេបញ្ជាមកយើងធ្វើអីធ្វើហ្នឹងហ្នឹង
យើងទៅខ្លាចអី!!

កះហ៊ឺៗ!!

ខះហើយដល់ហើយគេថាគេចោតយើងថាខ្ញុំនេះសូកប៉ាន់គេដូចថាអ្នក១៧អ៊ីចឹង
ដូចជំនាន់លន់ នល់គេហៅថាចុះយើង ដូចថាអ្នក១៧មកយើងបានយកមាសគេរាប់ដំឡឹង
ឯងថាអូយ!!ពុទ្ធោអើយញ៉ុមមិនដែលឃើញមាសទេគេដូរអង្ករគេដូរមួយតៅអង្ករមួយដំឡឹងមាស។

កះហ៊ឺៗ!!

ខះអាហ្នឹងបានគេបាន!!

កះហ៊ឺៗ!!

ខះបើសិនជាទៅយករបស់គេអត់ទេ!!បើយើងចង់បានយើងយកដំឡូងមកដូរមានពោតមានអីពោតកិនជួលកាលពោតមូលជូនកាលគ្នាចង់បានធ្វើស្ងោរពោតបបរវីកបានទឹកបបរវីកច្រើនកូនស៊ីគ្នាដូរទៅ!!

កះហ៊ឺៗ!!

ខះហើយញ៉ុមកំរណាស់តែញ៉ុមមានពោតមានចែក២
កំប៉ុង៣កំប៉ុង៤កំប៉ុងអញ្ចឹងទៅចេះតែចែកគេទៅព្រោះញ៉ុមមិនសូវមានកូន។

កះចាំ!!

ខះនឹកឃើញយើងអត់កូនគ្នាមានកូនច្រើនណាស់គ្នាបានស្ងោរអ៊ីចឹងគ្រាន់កូនរើសស៊ីទៅឆ្អែតដែរកូនណាស់ស្ងោរពោតទឹកកំបោរកូនណាស់!!

កះចាំ !!

ខះហើយអង្ករមួយគីឡូ២គីឡូអោយគ្នាទៅ!!អាហ្នឹងបើញ៉ុមមាន
បើញ៉ុមអត់សហករណ៍គេថ្លឹងមួយពែងប៉ុននេះមួយខាំម្នាក់ហ្នឹងខ្ញុំបានរបបដូចគ្នាហ្នឹង!!មានលើសឯណា
អាខ្លះគ្នាកូនច្រើនទៅបបរលាយផ្ទីលាយអីអ៊ីចឹងទៅណាស់កូន!!ហើយខ្ទុះលាយត្រកួនហាន់ត្រកួនស្ងោរវាពូតស្រក់ពូតវាអោយស្រក់ទឹកយកវាយើងដាំបាយហ្នឹងយើងជ្រោយៗវាទៅ។

កៈចាំ!!

ខៈមានអីឆ្ងាញ់ដែរតើ!!

កៈអញ្ចឹងអ៊ំម៉េចវិញទៅបានអ៊ំរួចខ្លួនចេញពីអាកន្លែងគេជាប់ឃុំឃាំងពេលបែកហ្នឹងមក?

ខៈ អើរដល់យូរ!!ដល់មួយខែពីរខែបានគេធ្វើស្រាវជ្រាវប្រវត្តិរូបហាំ!!

កៈហ៊ឺៗ!!

ខៈគេហៅយើងប្រជុំគេហៅឈ្មោះគេអោយយើងចេញណាស់គេប្រាប់យើងឈ្មោះ
ដល់៧ថ្ងៃគេហៅឈ្មោះយើងចេញ!!ខ្ញុំដើររហូតតាំងពីរទួលទំពូងមករហូតមកយើង
មកដល់ស្រែកទឹកពេកនៅអាលែងច្រៃមច្រំហ្នឹង
អើរអស់ជើងហើយហាំ!!!មីអស់ហ្នឹងដាំបាយស៊ីហាំ??គេអោយអង្ករពោតសាលី២កំប៉ុង២កំប៉ុង
ម្នាក់ដាំបាយកន្លែងទួលហ្នឹងទៅ!!

កៈហ៊ឺ!!

ខៈស្រុះហ្នឹងហើយដល់ហើយមីអូនហាំដល់ស្រែកទឹកពេកចុះទៅក្នុងប្រលាយហ្នឹងអោនផឹកច
ង់ដាំ!!

កៈដាំដូងចូល!!

ខៈ ដាំដូងចូលចង់បាស់ជើងបាស់ដៃហ្នឹងហាំ!

កៈចាំ!!

ខៈអស់ពេក
ថាហ្អែងស៊ីអោយអស់ទៅអញស៊ីតែក្តាំងៗទេហាំ!!ស៊ីក្តាំងៗគេមកដល់ផ្ទះម៉ែអីបានឃំតើ!!

កៈ ស្មានតែស្លាប់បាត់ហើយអ៊ំហេ?

ខៈ ស្មានតែស្លាប់បាត់ហើយ!!

កៈអញ្ចឹងពីរនាក់ប្តីប្រពន្ធនៅហ្នឹងទាំង២ហេ?

ខ៖ នៅហ្នឹងទាំងពីរ ប្តីញ៉ុម
ញ៉ុមចេញមកហ្នឹងបានមួយខែបានប្តីញ៉ុមចេញដល់ចូលឆ្នាំហើយបានគេអោយមក!!

ក៖ហូ!!នៅស្រាវជ្រាវទៀតហោ?

ខ៖ហ្នឹងហើយ។អាខ្លះគេអត់ទាន់ចេញទេទាល់តែបែកហើយបានចេញ!!

ក៖ហើយម៉េចដែរអ៊ំដល់ពេលបែកមករកស៊ីដាំដុះអីវ៉ាន់ដូចធម្មតាអ៊ីចឹងទៅ?

ខ៖យើងចូលសហករណ៍ហ្នឹង។

ក៖ចាំ!!

ខ៖ដូចថា១០គ្រួសារ ១៥គ្រួសារមួយសហករណ៍អ៊ីចឹងទៅណាស់!!
គេដាំថ្នាំកាតាបយើងដាំថ្នាំកាតាបអីដាំស្អីយើងទៅ!!

ក៖អាហ្នឹងពេលបែកប៉ុល ពតហើយហើយ!!

ខ៖ ចាំ!!

ក៖តែក៏លែងមានទាហានប៉ុល ពតអីមកយាយីហើយ?

ខ៖ អត់មានអាណាមកលេងរញ៉េរញ៉ៃហើយ!!ចូលក្នុងក្រុមសហករណ៍ហើយហ្នឹងហិ!!!!

ក៖ចាំអញ្ចឹងយើងមានអ្នកគ្រប់គ្រងអីភូមិ!!

ខ៖ គ្រប់គ្រងប្រធានភូមិឃុំអីមានហើយ។

ក៖អញ្ចឹងចាប់ផ្តើមចែកដីចែកអីហើយអំណោះ?

ខ៖អើរមានគ្រួសារគេចែកដីហើយណាស់!!

ក៖ចាំអញ្ចឹងរស់នៅដោយសុខសាន្តមក។

ខ៖ចាំ!!

ក៖អត់មានសង្គ្រាមមានអីទៀតទៅ!

ខ៖អត់!!

ក៖ចាំ!!ហ្នឹងហើយ
ចាំអ៊ីចឹងអរគុណច្រើនមែនទែនអ៊ំសំរាប់ការសំភាសន៍ដ៏ក្បោះក្បាយអ៊ំបាននិយាយរៀបរាប់ល្អណាស់ អ៊ីចឹងកូនចៅអ៊ំគាត់នឹងឮទាំងអស់ហ្នឹងអ៊ំណាស់!!

ខ៖ចាំ!!

ក៖ចាំអញ្ចឹងអរគុណច្រើនណាស់អ៊ំ!!

ខ៖ចាំ។